ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# កម្មវិធីសាលាកុមារមេត្រី

## សមាសភាគទី ២ : ប្រសិទ្ធភាពនៃការបង្រៀន និង រៀន

## គោលវិធីសិស្សមជ្ឈមណ្ឌល



ឯកសារគាំទ្រការអនុវត្ត

សៀវភៅកំណត់ត្រាគ្រូ

# **អារម្ភកថា**

សៀវភៅប្រសិទ្ធភាពនៃការបង្រៀន និង រៀន ( ETL ) ត្រូវបានរៀបរៀងក្នុងក្របខណ្ឌសមាសភាគទី ២ នៃកម្មវិធី សាលាកុមារមេត្រី ជា ២ សៀវភៅ : សៀវភៅអ្នកសម្របសម្រួល និង សៀវភៅកំណត់ត្រាគ្រូ ។

ទំរង់នៃសំណេរមាន ២ គឺ :

-ទំរង់ជាការបំប៉ន

-ទំរង់ជាលំហាត់កិច្ចការដោយផ្អែកលើសកម្មភាពដែលបានបង្រៀនកន្លងមក ។

ខ្លឹមសារនៃសៀវភៅបានពណ៌នាចំនួន ៨ មេរៀនសំខាន់ៗ ដែលនឹងអាចពង្រីកសមត្ថភាពក៏ដូចជាបទពិសោធ ជូនគ្រូឈរថ្នាក់ឱ្យមានការអភិវឌ្ឍមួយកំរិតថែមទៀត ទាំងរបៀបរបបការងារ ទាំងបច្ចេកទេសបង្រៀន ។ ខ្លឹមសារមេរៀនបានផ្តល់នូវ គំនិតផ្តួចផ្តើមជាច្រើនសម្រាប់ការបង្រៀនដូចជា :

-ការបង្កើតល្បែងសិក្សាច្រើនបែបសម្រាប់មុខវិជ្ជាគោលទាំង ៤

-ការច្នៃប្រឌិតប្រើប្រាស់ប័ណ្ណផ្សព្វផ្សាយផ្សេងៗ : ផ្ទាំងរូបភាព ឯកសារ... ដែលបំរើឱ្យសេវាសង្គម ( **អប់រំ សុភាព ពាណិជ្ជកម្ម បរិស្ថាន... ។ល។** ) មកបំរើឱ្យការរៀនរបស់កុមារបានល្អប្រសើរ

-ល្បិចជួយកុមារដើម្បីអភិវឌ្ឍបំណិនអាន សំណេរ និង ការគិត ( បញ្ហា )... ។

សៀវភៅប្រសិទ្ធភាពនៃការបង្រៀន និង រៀន (ETL) មានគោលដៅតែមួយគត់ គឺអភិវឌ្ឍបុគ្គលិកលក្ខណៈ ពេញលេញរបស់កុមារគ្រប់រូប ។

គណៈកម្មការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រី នឹងចងក្រងសកម្មភាពមេរៀនជាលក្ខណៈប្រតិបត្តិបន្តបន្ទាប់ទៀត សម្រាប់ជាជំនួយស្មារតីជូនលោកគ្រូ អ្នកគ្រូជាទីស្រឡាញ់ និង រងចាំទទួលមតិកែលំអពីលោកអ្នកជានិច្ច ។

**អរគុណ !**

# <u>បញ្ជីប្រធានបទ</u>

ទំព័រ

-សេចក្តីផ្តើម គោលបំណង ខ្លឹមសាររួម.....................................................................................១

**ប្រធានបទទី ១ :** ការគ្រប់គ្រងថ្នាក់រៀន ៥ សកម្មភាព.......................................................................២-៥

**ប្រធានបទទី ២ :** ការប្រើប្រាស់សំណួរ ៥ សកម្មភាព.......................................................................៦-១៨

**ប្រធានបទទី ៣ :** ការបង្កើតល្បែងសិក្សា ៦ សកម្មភាព..............................................................១៩-២៦

**ប្រធានបទទី ៤ :** ការប្រើប្រាស់ធនធានក្នុងថ្នាក់រៀនសំបូរបែប ៥ សកម្មភាព.................................២៧-៣១

**ប្រធានបទទី ៥ :** ការអភិវឌ្ឍអំណាន ៤ សកម្មភាព..................................................................៣២-៣៧

**ប្រធានបទទី ៦ :** ការអភិវឌ្ឍសំណេរ ៣ សកម្មភាព..................................................................៣៨-៤៣

**ប្រធានបទទី ៧ :** វាយតម្លៃ/កម្រងស្នាដៃសិស្ស ៤ សកម្មភាព......................................................៤៤-៤៦

**ប្រធានបទទី ៨ :** ការឆ្លុះបញ្ចាំងគ្រូ ( ស្វ័យវាយតម្លៃ ) ៤ សកម្មភាព............................................៤៧-៥១

**ឧបសម្ព័ន្ធ**

គ្រូ : ..........................................................................

ថ្នាក់ទី : .........................................................................

សាលារៀន : .........................................................................

កម្រងសាលារៀន : .........................................................................

ស្រុក/ខណ្ឌ : .........................................................................

ខេត្ត/ក្រុង : .........................................................................

ឆ្នាំសិក្សា : .........................................................................

# គ្រូបង្រៀនសាលាកុមារមេត្រី

### សារៈសំខាន់នៃគ្រូបង្រៀននៅក្នុងសាលាកុមារមេត្រី

### ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀន សម្រាប់អភិវឌ្ឍវិជ្ជាជីវៈ

### គ្រូបង្រៀន គឺជាគន្លឹះសម្រាប់អនុវត្តកម្មវិធីសាលាកុមារមេត្រីប្រកបដោយជោគជ័យ

គ្រូជាអ្នកពាក់ព័ន្ធយ៉ាងសំខាន់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ ដើម្បីកែលំអគុណភាពសាលារៀន នៅក្នុងប្រព័ន្ធអប់រំ ។ គ្រូមានឥទ្ធិពលយ៉ាងច្រើនទៅលើកុមារដែលពួកគាត់បង្រៀន និងថ្នាក់រៀនដែលពួកគាត់គ្រប់គ្រង ។ មនុស្សភាគច្រើនមានការកត់សំគាល់យ៉ាងងាយចំពោះគ្រូល្អ និងគ្រូអន់ ។

គ្រូដើរតួជាគំរូដល់សិស្សនៅក្នុងថ្នាក់រៀនរបស់គាត់ ។ គ្រូអាចបង្ហាញនូវបុគ្គលិកលក្ខណៈល្អ ដែលគ្រួសារភាគច្រើនចង់ ឃើញកូនរបស់ខ្លួនយកតម្រាប់តាម ។ គុណភាពទាំងនេះរួមមាន ការខំប្រឹងប្រែងធ្វើការងារ មានចិត្តសប្បុរស មិនលំអៀង និងគោរពដល់អារម្មណ៏របស់អ្នកដទៃ ជាពិសេសសិទ្ធិរបស់កុមារ ។ គុណភាពទាំងនេះ គឺជាផ្នែកទាំងមូលរបស់បញ្ញត្តិនៃកម្មវិធីសាលាកុមារមេត្រី ។

គ្រូកុមារមេត្រីត្រូវតែស្គាល់កុមារគ្រប់រូបទាំងអស់នៅក្នុងថ្នាក់ខ្លួន ។ គ្រូត្រូវតែស្គាល់ឈ្មោះ ស្ថានភាពគ្រួសារ ចំណុចខ្លាំង ចំណុចខ្សោយ និងចំណង់ចំណូលចិត្តរបស់ពួកគេ ។ គ្រូកុមារមេត្រីត្រូវស្តាប់គំនិត និងមតិរបស់កុមារនៅក្នុងថ្នាក់របស់ខ្លួន ។ គ្រូកុមារមេត្រីត្រូវតែទទូចឱ្យកុមារនៅក្នុងថ្នាក់ស្តាប់គ្នាទៅវិញទៅមកផងដែរ ។ ប្រសិនបើគ្រូពិតជាគោរពតម្លៃនៃបទពិសោធន៏ និងទស្សនៈរបស់កុមារនោះ កុមារក៏នឹងធ្វើដូច្នោះដែរ ។

### ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ជាផ្នែកមួយនៃកម្មវិធីសាលាកុមារមេត្រី

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីបំប៉នថ្នាក់ជាតិដល់បុគ្គលិកសិក្សាទាំងអស់ សម្រាប់ជាផ្នែកនៃការពង្រីកកម្មវិធីសាលាកុមារមេត្រី ។ ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀន គឺជាកិច្ចខំប្រឹងប្រែងចម្បងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឱ្យបានទៅដល់គ្រូគ្រប់រូបទូទាំងប្រទេស ។

កម្មវិធីសាលាកុមារមេត្រីមានឬគ្មានផលប៉ះពាល់ដល់សាលារៀន អាស្រ័យទៅលើអ្វីដែលលោកគ្រូ អ្នកគ្រូបានធ្វើ ។ ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀនរួមបញ្ចូលទាំងឯកសារអភិវឌ្ឍវិជ្ជាជីវៈ ក្រសួងនឹងផ្តល់ជូនផ្ទាល់ដល់ដៃគ្រូ ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានអំពីគំនិតថ្មីៗនៅក្នុងការបង្រៀន និងរៀន និងឧទាហរណ៏សម្រាប់អនុវត្តជាក់ស្តែងអំពីរបៀបដែលគ្រូអាចប្រើគំនិតថ្មីៗទាំងនេះនៅក្នុងថ្នាក់រៀន ។

ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្តល់ផងដែរនូវការគាំទ្រដល់គ្រូតាមសាលារៀនពេញមួយឆ្នាំសិក្សា តាមរយៈគ្រូឧទ្ទេសមកពីកម្រងសាលារៀន ឬការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ខណ្ឌ ។

សៀវភៅកំណត់ត្រាគ្រូ គឺជាផ្នែកមួយរបស់ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។ សៀវភៅកំណត់ត្រានេះ គឺសម្រាប់គ្រូកត់ត្រាកិច្ចការដែលបានធ្វើក្នុងឆ្នាំសិក្សា ។ គ្រូអាចយកសៀវភៅកំណត់ត្រារបស់ខ្លួនមកកាន់អង្គប្រជុំ

អភិវឌ្ឍវិជ្ជាជីវៈ ដែលប្រារព្ធធ្វើនៅកម្រងសាលារៀន ឬ នៅការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ខណ្ឌ ។ គ្រូអាចចែករំលែកលទ្ធផលបទពិសោធការងាររបស់ខ្លួនជាមួយគ្រូដទៃទៀតបាន និង ជួយដល់គ្នាទៅវិញទៅមក ដើម្បីបំពេញឱ្យបានចប់សព្វគ្រប់នៅក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ ។

នៅដំណាច់ឆ្នាំសិក្សា គ្រូគួរជូនសៀវភៅកំណត់ត្រាគ្រូទៅលោកនាយក/នាយិកាដើម្បីពិនិត្យមើល ។ គ្រូដែលបានអនុវត្តនូវរាល់កិច្ចការទាំងអស់នៅក្នុងថ្នាក់រៀនរបស់ខ្លួន ហើយបានកត់ត្រាលទ្ធផលនានា គ្រូនោះនឹងទទួលបានការលើកទឹកចិត្តពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកទឹកចិត្តដល់ការចូលរួមយ៉ាងសកម្មរបស់គាត់នៅក្នុងកម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។

# ប្រសិទ្ធភាពនៃការបង្រៀន និង រៀន

## I.សេចក្តីផ្តើម

សាលាកុមារមេត្រី គឺជាក្របខណ្ឌទូលំទូលាយមួយដែលមានគ្រប់ផ្នែកនៃការងារទាំងអស់របស់សាលារៀន រួមមាន ការគ្រប់គ្រងសាលារៀន សុខភាព និង សុវត្ថិភាព យេនឌ័រ ទំនាក់ទំនងសាលារៀន និង សហគមន៍ និង ការគាំទ្ររបស់ប្រព័ន្ធអប់រំ ។ សកម្មភាពប្រសិទ្ធភាពនៃការបង្រៀន និង រៀន សមាសភាគទី២ នៃកម្មវិធីសាលាកុមារមេត្រី ត្រូវបានចងក្រងជា ២ ឯកសារដាច់ដោយឡែកពីគ្នា :

១.សៀវភៅអ្នកសម្របសម្រួល

២.ឯកសារសម្រាប់គ្រូឈរថ្នាក់ ហៅថា " **សៀវភៅកំណត់ត្រាគ្រូ** "

សៀវភៅកំណត់ត្រាគ្រូនឹងត្រូវចែកជូនដល់គ្រប់គ្រូទាំងអស់ សម្រាប់កត់ត្រាកិច្ចការដែលបានអនុវត្តនៅក្នុងឆ្នាំសិក្សា ។ គ្រូអាចយកសៀវភៅកំណត់ត្រារបស់ខ្លួនមកកាន់អង្គប្រជុំដែលប្រារព្ធធ្វើនៅកម្រងសាលារៀន ឬ នៅការិយាល័យអប់រំ យុវជន និង កីឡាស្រុក/ខណ្ឌរៀងរាល់ខែ ។ គ្រូនឹងបានចែករំលែកលទ្ធផលបទពិសោធការងាររបស់ខ្លួនជាមួយគ្រូដទៃទៀត បាន និង ជួយដល់គ្នាទៅវិញទៅមក ដើម្បីបំពេញឱ្យបានចប់សព្វគ្រប់នៅក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ ។ សៀវភៅកំណត់ត្រានេះនឹងជួយគ្រូឱ្យសាកល្បងអនុវត្តជាក់ស្តែងនូវគំនិតថ្មីៗ និង ឱ្យពួកគាត់អាចក្លាយទៅជាអ្នកស្រាវជ្រាវនៅក្នុងថ្នាក់រៀន ។

## II.គោលបំណង

ដើម្បីឱ្យលោកគ្រូ អ្នកគ្រូកែលំអគុណភាពនៃការរៀនសូត្ររបស់សិស្ស ដោយការអនុវត្តវិធីបង្រៀន និង រៀន តាមបែបកុមារមេត្រី ។

## III.ខ្លឹមសារ

ប្រសិទ្ធភាពនៃការបង្រៀន និង រៀន រួមមាន :

១.ការគ្រប់គ្រងថ្នាក់រៀន

២.ការប្រើប្រាស់សំណួរ

៣.ការបង្កើតល្បែងសិក្សា

៤.ការប្រើប្រាស់ធនធានក្នុងថ្នាក់រៀនសំបូរបែប

៥.ការអភិវឌ្ឍអំណាន

៦.ការអភិវឌ្ឍសំណេរ

៧.រង្វាយតម្លៃ និង កម្រងស្នាដៃសិស្ស

៨.ការឆ្លុះបញ្ចាំង ( ស្វ័យវាយតម្លៃ )

ឯកសារឧបសម្ព័ន្ធ

IV.សកម្មភាពអនុវត្ត

# ១.ប្រធានបទទី១ : ការគ្រប់គ្រងថ្នាក់រៀន

## ព័ត៌មានសម្រាប់គ្រូ

គ្រូទទួលខុសត្រូវក្នុងការគ្រប់គ្រងថ្នាក់រៀនរបស់ខ្លួន ។ វិធីនៃការរៀបចំថ្នាក់រៀន អាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើរបៀបរៀនរបស់កុមារ ។ ឧទាហរណ៍ : ប្រសិនបើគ្រូតុបតែងថ្នាក់ហើយមិនដែលផ្លាស់ប្តូរ ឬប្រើប្រាស់វត្ថុទាំងនោះបម្រើឱ្យការបង្រៀន និង រៀនទេ កុមារនឹងធុញទ្រាន់មិនចង់ចូលរួមការពិភាក្សា និង ធ្វើការងារជាមួយគ្នាឡើយ ។ កុមារពិតជារៀនដោយការស្តាប់គ្រូ ឬចម្លងពីសៀវភៅសិក្សាគោល ឬក្តារខៀនតែប៉ុណ្ណោះ ។ គួរមានរបៀប រៀនដទៃទៀតដែលមានប្រសិទ្ធភាពជាងនេះ ។ កុមាររៀនបានពូកែនៅពេលដែលពួកគេរៀនយ៉ាងសកម្ម និងទទួលបានការលើកទឹកចិត្ត ។ គ្រូត្រូវក្តាប់ឱ្យបាននូវចំណាប់អារម្មណ៍របស់កុមារ និង ត្រូវផ្តល់កិច្ចការរៀនសូត្រជាច្រើនខុសៗគ្នា ។ ភាពប្លែកៗមានសារសំខាន់ណាស់សម្រាប់កុមារ ។ គ្រូគួរតែធ្វើកិច្ចតែងការបង្រៀន ដើម្បីឱ្យកុមារមានឱកាសធ្វើការងារដោយខ្លួនឯង ជាដៃគូ ក្រុមតូច ក្រុមធំ ឬថ្នាក់ទាំងមូល ។

គ្រូនិងសិស្ស ចូលចិត្តធ្វើការងារនៅក្នុងបន្ទប់រៀនដែលមានភាពទាក់ទាញនិងគួរឱ្យចាប់អារម្មណ៍ ។ នេះមានន័យថា:

- រក្សាបន្ទប់រៀនឱ្យស្អាត
- មានធុងដាក់សម្រាម និងចាក់វាចោលជារៀងរាល់ថ្ងៃ
- សម្អាត និងរៀបចំក្តារខៀនជារៀងរាល់ថ្ងៃ
- រៀបចំគ្រឿងសង្ហារិម ដើម្បីឱ្យកុមារអាចរៀនតាមរបៀបផ្សេងៗពីគ្នា ( ដោយខ្លួនឯង ជាដៃគូ ក្រុមតូច ក្រុមធំ ថ្នាក់ទាំងមូល )
- ដាក់ប័ណ្ណរូបភាពពណ៌ តារាងផ្សេងៗ ផែនទី និងដាក់តាំងរូបគំនូរនៅលើជញ្ជាំង
- ធ្វើ និងដាក់តាំងប័ណ្ណពាក្យ ពាក្យស្លោក ស្លាកសញ្ញា ប្រយោគ សំណួរ
- ដាក់តាំងកិច្ចការផ្ទាល់ខ្លួនរបស់សិស្ស នៅលើជញ្ជាំង ឬក៏ចងព្យួរនឹងខ្សែ
- មានកន្លែងពិសេសនៅក្នុងបន្ទប់ ( *ឧទាហរណ៍:* សម្រាប់តារាង សៀវភៅបណ្ណាល័យ ទស្សនាវដ្តី អំបោស កញ្ចក់ក្រាស កន្លែងវាស់កម្ពស់ ថ្លឹងទម្ងន់កុមារ ...) ។
- ព្យួរប័ណ្ណរូបភាព រូបភាព និងផែនទីដែលមានកំពស់ ឱ្យកុមារអាចមើលឃើញច្បាស់

គ្រូប្រើគំនិតថ្មីៗរបស់ឯកសារនេះ នឹងធ្វើឱ្យមានការផ្លាស់ប្តូរខ្លះៗ អំពីរបៀបដែលពួកគាត់រៀបចំ បន្ទប់រៀន ។ តាមរយៈការគូរ " ***ប្លង់បន្ទប់រៀន*** " នៅក្នុងពេលខុសៗគ្នានៃឆ្នាំសិក្សានីមួយៗ គ្រូអាចមើលឃើញពីការផ្លាស់ប្តូរនៅក្នុងការគ្រប់គ្រងបន្ទប់រៀនរាល់ពេល ។ ប្លង់បន្ទប់រៀន គួរតែគូរជាដ្យាក្រាម សាមញ្ញពុំមែនជារូបភាពឡើយ ។ ប្លង់បន្ទប់រៀននេះមិនត្រូវចំណាយពេលលើសពី១០នាទី ដើម្បីគូរឡើយ ។

## កិច្ចការគ្រូ

កិច្ចការសម្រាប់គ្រូដែលទាក់ទងទៅនឹងការគ្រប់គ្រងថ្នាក់រៀន គឺត្រូវប្លង់បន្ទប់រៀនរបស់គាត់ បីលើកក្នុងមួយនៃឆ្នាំសិក្សា៖

- **កិច្ចការគ្រប់គ្រងថ្នាក់រៀន ១ ( ប្លង់បន្ទប់រៀន គូរលើកទី ១)**

  គួរតែគូរនៅក្នុងសប្តាហ៍ដំបូងនៃការបង្រៀន នៅដើមឆ្នាំសិក្សា ( ខែតុលា)
- **កិច្ចការគ្រប់គ្រងថ្នាក់រៀន ២ ( ប្លង់បន្ទប់រៀន គូរលើកទី ២)**

  គួរតែគូរក្នុងពេលជិតដំណាច់ឆមាសទី១ នៃឆ្នាំសិក្សា ( ខែកុម្ភៈ)
- **កិច្ចការគ្រប់គ្រងថ្នាក់រៀន ៣ ( ប្លង់បន្ទប់រៀន គូរលើកទី ៣ ក្នុងរយៈពេលមួយឆ្នាំសិក្សា)**

  គួរតែគូរក្នុងពេលប្រហែលមួយខែមុនដំណាច់ឆ្នាំសិក្សា (ខែមិថុនា) ។ គ្រូនឹងត្រូវសរសេរអំពីគំនិត៣សំខាន់ៗដែលមានការផ្លាស់ប្តូរផងដែរ រវាងប្លង់បន្ទប់រៀនរៀបចំនៅលើកទី២ និងលើកទី៣ ។

**ប្លង់បន្ទប់រៀនគួរតែរាប់បញ្ចូលនូវ ៖**

- ទ្វារ និងបង្អួច
- ទីតាំងតុ និងកៅអី របស់សិស្ស និងគ្រូ
- ទីតាំងក្ដារខៀន
- ទីតាំងគ្រឿងសង្ហារិមដទៃទៀតរបស់ថ្នាក់រៀន ( ធ្នើរ កញ្ចក់ ក្រាស ធុងចម្រោះទឹក ធុងសំរាម ប្រអប់ តុទូសម្ភារ អំបោស ... )
- ឧបករណ៏ផ្សេងៗទៀតរបស់ថ្នាក់រៀន ( ប័ណ្ណរូបភាព ប្រធានបទនានា ផែនទី តារាងនានា រូបមន្ត... )
- កន្លែងដាក់តាំងកិច្ចការសិស្ស (ជញ្ជាំង ខ្សែ និងកន្លែងព្យួររូបភាព ... )
- កៀនបណ្ណាល័យ
- ធនធានសម្រាប់ការបង្រៀន និងរៀន
- វត្ថុដទៃទៀត ។

**កិច្ចការគ្រប់គ្រងថ្នាក់រៀន គួរលើកទី ១**

**ប្លង់បន្ទប់រៀន (ខែ តុលា ឆ្នាំ .........)**




**<u>សញ្ញាសំគាល់ ជ.ទី១</u>**

១.បាវចនាជាតិ

២.ព្រះឆាយាល័ក្ខ

៣.តារាងផ្សេងៗ

..............................

..............................

**<u>សញ្ញាសំគាល់ ជ.ទី៣</u>**

..............................

..............................

**<u>សញ្ញាសំគាល់ ជ.ទី២</u>**

..............................

..............................

**<u>សញ្ញាសំគាល់ ជ.ទី៤</u>**

..............................

..............................

## កិច្ចការគ្រប់គ្រងថ្នាក់រៀន គួរលើកទី ២

## ប្លង់បន្ទប់រៀន (ខែ កុម្ភៈ ឆ្នាំ ...........)

**សញ្ញាសំគាល់ ជ.ទី១**

..............................

..............................

ជញ្ជាំងទី១

**សញ្ញាសំគាល់ ជ.ទី៣**

..............................

..............................

ជញ្ជាំងទី២

ផ្ទៃបន្ទប់រៀន

ជញ្ជាំងទី៣

**សញ្ញាសំគាល់ ជ.ទី២**

..............................

..............................

ជញ្ជាំងទី៤

**សញ្ញាសំគាល់ ជ.ទី៤**

..............................

..............................

**ការផ្លាស់ប្តូរសំខាន់ៗនៅក្នុងបន្ទប់រៀន រវាងប្លង់ទី១ និង ប្លង់ទី២នៅក្នុងឆ្នាំសិក្សា**

១ ..............................................................................................................................

២ ..............................................................................................................................

៣ ..............................................................................................................................

យោបល់ផ្សេងៗ: ..........................................................................................................

..............................................................................................................................

## កិច្ចការគ្រប់គ្រងថ្នាក់រៀន គូរលើកទី ៣

## ប្លង់បន្ទប់រៀន (ខែ មិថុនា ឆ្នាំ ...........)

**សញ្ញាសំគាល់ ជ.ទី១**

..............................

..............................

ជញ្ជាំងទី១

**សញ្ញាសំគាល់ ជ.ទី៣**

..............................

..............................

ជញ្ជាំងទី២

ផ្ទៃបន្ទប់រៀន

ជញ្ជាំងទី៣

**សញ្ញាសំគាល់ ជ.ទី២**

..............................

..............................

ជញ្ជាំងទី៤

**សញ្ញាសំគាល់ ជ.ទី៤**

..............................

..............................

**ការផ្លាស់ប្តូរសំខាន់ៗនៅក្នុងបន្ទប់រៀន រវាងប្លង់ទី២ និង ប្លង់ទី៣ នៅក្នុងឆ្នាំសិក្សា**

**១** ..........................................................................................................................

**២** ..........................................................................................................................

**៣** ..........................................................................................................................

**យោបល់ផ្សេងៗ:** ...........................................................................................................

..........................................................................................................................

## ២.ប្រធានបទទី២ : ការប្រើប្រាស់សំណួរ

### ព័ត៌មានសម្រាប់គ្រូ

សំណួរគឺជាឧបករណ៍សំខាន់មួយសម្រាប់គ្រូ ។ ការសួរសំណួរគឺជាបំណិនមួយ ដែលគ្រូអាចកែលំអបាន តាមការអនុវត្តជាក់ស្តែង ។ គ្រូប្រើប្រាស់សំណួរដើម្បី :

- រកឃើញនូវអ្វីដែលកុមារដឹងរួចហើយអំពីប្រធានបទ (សមត្ថភាពមានស្រាប់) មុននឹងចាប់ផ្តើមបង្រៀន
- ពិនិត្យមើលការយល់ដឹងរបស់កុមារអំពីអ្វីដែលពួកគេបាននិងកំពុងតែរៀន
- អភិវឌ្ឍសមត្ថភាពស្តាប់ និងនិយាយរបស់កុមារ
- ឱ្យកុមារនិយាយអំពីបទពិសោធផ្ទាល់ខ្លួនគេ
- ឱ្យកុមារបញ្ចេញគំនិត និងមតិពួកគេ
- ឱ្យការបង្រៀនកាន់តែមានលក្ខណៈសិស្សមជ្ឈមណ្ឌល

☞ គ្រូគួរតែទម្លាប់សិស្សឱ្យសួរសំណួរទៅកាន់គ្នាគេ និងគ្រូផងដែរ ។

គ្រូភាគច្រើនបានដឹងរួចហើយថា មានសំណួរច្រើនប្រភេទ និងកម្រិតផ្សេងៗគ្នា។ *ឧទាហរណ៍* : ប្រសិនបើ គ្រូសួរទៅសិស្សនូវអ្វីដែលគេបានរៀនរួចហើយនោះគឺជាសំណួរ**ចងចាំ**។ ប៉ុន្តែប្រសិនបើគ្រូសួរសិស្ស នូវអ្វីដែលសិស្សមិនអាចឆ្លើយភ្លាមៗ បាន ហើយតម្រូវឱ្យសិស្សធ្វើការពិចារណា មុននឹងឆ្លើយ នោះគឺជាសំណួរ**ត្រិះរិះ/ពិចារណា** ។

សំណួរពិចារណា មានកម្រិតខុសៗគ្នា ។ សំណួរពិចារណាខ្លះ តម្រូវឱ្យសិស្សមើលនិងស្តាប់ ហើយបន្ទាប់មកត្រូវបង្ហាញថា ពួកគេយល់ និងអាចពន្យល់បាន។ សំណួរទាំងនេះអាចហៅថា សំណួរ**យល់ដឹង** ។ ដើម្បីឆ្លើយសំណួរជាដំបូង កុមារត្រូវតែយល់ និង**បន្ទាប់មក**ធ្វើការពិចារណាបន្ថែមទៀត ដើម្បីបង្កើតជាចម្លើយ ។ ការគិតពិចារណាបន្ថែមទៀតអាចទាក់ទងនឹង:

- ការយល់ដឹងពីបញ្ញត្តិ វិធាន រូបមន្ត គោលការណ៍ និងការប្រើប្រាស់នៅក្នុងស្ថានភាពមួយទៀត (**ការអនុវត្ត**)
- ការបញ្ចូលគំនិតច្រើនជាមួយគ្នា ដើម្បីបង្កើតគំនិតថ្មី (**ការសំយោគ**)
- ការពិនិត្យមើលបណ្តុំគំនិត ឬព័ត៌មាន និងកំណត់ពីភាពដូចគ្នា ភាពខុសគ្នា និងទំនាក់ទំនងរវាងគ្នា (**ការវិភាគ**)
- ការពិនិត្យមើលឡើងវិញនូវបណ្តុំគំនិត ឬ ព័ត៌មាន និងផ្តល់មតិផ្ទាល់ខ្លួនអំពីគុណភាពរបស់វា (ចំនួន ទំហំ ប្រសិទ្ធភាព ថ្លៃចំណាយ...។ល។) (**ការវាយតម្លៃ**)

សំណួរទាំងនេះគឺជា សំណួរ**ពិចារណាឬគំរិតខ្ពស់** ពីព្រោះគេត្រូវតែគិតដោយខ្លួនឯង និងបង្កើតគំនិត ឬ ព័ត៌មានថ្មីដើម្បីឆ្លើយ ។

## តារាងសង្ខេបនូវសំណួរពាកម្រិត និង លក្ខណៈរបស់សំណួរ

| កម្រិតសំណួរ | កម្រិតនៃការគិត/សកម្មភាព ដែលចាំបាច់ដើម្បីឆ្លើយ |
|---|---|
| សំណួរចងចាំ | **នឹកឃើញ ចងចាំ**<br>អ្វីមួយដែលបានរៀនរួច |
| សំណួរយល់ដឹង | **យល់ដឹង ពន្យល់**<br>ទៅតាមរបៀបផ្សេងពីគំនិត ឬ ព័ត៌មានដែលបានផ្តល់ឱ្យ |
| សំណួរពិចារណាហ្មត់ចត់ | **យល់ដឹង និងបង្កើតគំនិតថ្មី**<br>ប្រៀបធៀប បង្ហាញភាពផ្ទុយគ្នា បកស្រាយ អនុវត្ត ស្រាវជ្រាវ<br>រកហេតុផល វិភាគ ធ្វើសម្មតិកម្ម វាយតម្លៃ កំណត់អាទិភាព |

គ្រូអាចប្រើសំណួរទាំងបីកម្រិតនេះជាមួយកុមារគ្រប់អាយុទាំងអស់ ។ ពុំមានអ្វីខុសឆ្គងឡើយក្នុងការប្រើសំណួរ **ចងចាំ និងយល់ដឹង** ដោយសំណួរទាំងនេះមានសារៈសំខាន់នៅក្នុងការស្វែងយល់ភ្លាមៗ ថាតើកុមារយល់ឬមិនយល់មេរៀន។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលកុមារកាន់តែធំ វាជាការសំខាន់ចំពោះគ្រូ ក្នុងការផ្តល់នូវសំណួរពិចារណាហ្មត់ចត់ឱ្យបានច្រើនទៀត និងធ្វើឱ្យសំណួរទាំងនេះកាន់តែមានភាពលំបាក ។ ជារឿយៗការធ្វើដូចនេះ មានន័យថាត្រូវសួរកុមារដោយផ្ទាល់ដើម្បី ឱ្យពួកគេផ្តល់នូវមតិ និងពន្យល់ពីមូលហេតុ។

## កិច្ចការគ្រូ

### កិច្ចការទី 1

ប្រមូលសំណួរពិចារណាហ្មត់ចត់ចំនួនប្រាំ ដែលបានប្រើក្នុងមេរៀនបង្រៀនរួចហើយដាក់ក្នុងតារាង (ទំព័របន្ទាប់) ។ សំណួរទាំងនេះអាចដកស្រង់ពីមុខវិជ្ជាណាមួយក៏បាន ។

កិច្ចការនេះសម្រាប់ប្រជុំប្រចាំខែលើកទី៤ (ខែ មករា) ។

### កិច្ចការទី 2

ប្រមូលសំណួរពិចារណាហ្មត់ចត់ចំនួនប្រាំទៀត ដែលបានប្រើក្នុងមេរៀនបង្រៀនរួចហើយដាក់ក្នុងតារាង (ទំព័របន្ទាប់) ។ សំណួរទាំងនេះ អាចដកស្រង់ពីមុខវិជ្ជាណាមួយក៏បាន ។

កិច្ចការនេះសម្រាប់ការប្រជុំប្រចាំខែលើកទី៥ (ខែ កុម្ភៈ) ។

## កិច្ចការទី ១

| លេខរៀង | សំណួរពិចារណាហ្មត់ចត់ |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |
| ៥ | |

## កិច្ចការទី ២

| លេខរៀង | សំណួរ ពិចារណាហ្មត់ចត់ |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |
| ៥ | |

## ៣.ប្រធានបទទី៣ ៖ ការបង្កើតល្បែងសិក្សា

### ព័ត៌មានសម្រាប់គ្រូ

ល្បែងសិក្សាមានសារសំខាន់ណាស់ចំពោះគ្រូនិងសិស្ស។ សិស្សរីករាយលេងល្បែង ដែលអាចជួយឱ្យបរិយាកាសថ្នាក់រៀនមានភាពរស់រវើក និង សប្បាយរីករាយ ។ ល្បែងអាចលេងដោយថ្នាក់ទាំងមូល តាមក្រុមតូចៗ មានប្រសិទ្ធភាពណាស់ ពីព្រោះនៅពេលដែលសិស្សលេង ពួកគេក៏បានអភិវឌ្ឍសមត្ថភាពនិយាយ ស្តាប់ និង សហការជាមួយសិស្សដទៃទៀត (**បំណិនសង្គម និងតម្លៃ**)។ កុមារជាច្រើនរៀនបានពូកែ នៅពេលដែលពួកគេមានឱកាសពិភាក្សា អំពីការរៀនសូត្រថ្មីៗជាមួយសិស្សដទៃទៀត (**ការរៀនពីគ្នាឯង**) ។

គ្រូអាចផ្តល់ល្បែងសិក្សាទៅឱ្យសិស្សដែលបានបញ្ចប់កិច្ចការមុនគេ និងមានពេលទំនេរ ។ នៅពេលដែលកុមារទាំងនេះកំពុងតែលេងល្បែងសិក្សា គ្រូអាចធ្វើកិច្ចការជាមួយសិស្សដែលត្រូវការជំនួយផ្ទាល់ ។ គ្រូបង្រៀនថ្នាក់គួបអាចប្រើល្បែងសិក្សាសម្រាប់ផ្តល់ជាសកម្មភាពរៀនទៅឱ្យក្រុមសិស្សកម្រិតថ្នាក់មួយ (**ការរៀនដោយខ្លួនឯង**) ស្របពេលដែលគាត់កំពុងបង្រៀន សិស្សកម្រិតថ្នាក់មួយទៀត ។

ល្បែងសិក្សាមានច្រើនប្រភេទដែលកុមារចូលចិត្តលេង ដើម្បីបំពេញបន្ថែមនូវអ្វីដែលពួកគេបានរៀនរួចហើយ (**ការ**ពង្រឹងបន្ថែម) ។ កុមារលេងល្បែងដើម្បីអភិវឌ្ឍបំណិន និងការយល់ដឹងផងដែរ (ការពង្រីកការធ្វើឱ្យសំបូរបែប)។ ល្បែងសិក្សាអាចជំរុញកុមារបន្ថែមទៀតពីលើអ្វីដែលពួកគេបានដឹងរួចហើយ ដើម្បីដោះស្រាយបញ្ហាដោយធ្វើការសម្រេចចិត្ត ឬបង្កើតមតិយោបល់ ។ ល្បែងទាំងនេះជំរុញឱ្យមាន " **ការពិចារណាហ្មត់ចត់** "។

នៅក្នុងវគ្គបំប៉នគ្រូនឹងរៀនអំពីល្បែងបីប្រភេទ ដែលអាចលេងនៅកម្រិតថ្នាក់ណាមួយក៏បាន ហើយស្របទៅនឹងខ្លឹមសារសៀវភៅសិក្សាគោល ឬប្រភពផ្សេងទៀតដែលទាក់ទងលើគ្រប់មុខវិជ្ជា ។ ភាគច្រើននៃល្បែងទាំងនេះប្រើសម្ភារងាយៗដូចជាៈ បន្ទះក្តារ ប័ណ្ណ សន្លឹកក្រដាស ឬវត្ថុផ្សេងៗ ។

ល្បែងទាំងបីប្រភេទនេះ គឺ ៖

| **ប្រភេទល្បែង** | **បរិយាយ** |
|---|---|
| **ផ្គូផ្គង** | រកគូវត្ថុដែលដូចគ្នា រកវត្ថុដែលខុសប្លែកពីគេ |
| **រៀបតាមលំដាប់** | រៀបវត្ថុដាក់តាមលំដាប់ដោយអនុវត្តតាមច្បាប់ គោលការណ៍ ឬ វិធីដែលធ្លាប់អនុវត្ត |
| **ធ្វើចំណែកថ្នាក់** | ផ្គុំវត្ថុ ដោយអនុវត្តតាមលក្ខណៈ ឬ និយមន័យខ្លះ |

***បញ្ជាក់ ៖*** *ក្រៅពីល្បែងសិក្សាទាំងបីប្រភេទខាងលើ គ្រូអាចបង្កើតប្រភេទល្បែងសិក្សាផ្សេងៗទៀត តាមការច្នៃប្រឌិត និង លទ្ធភាពរបស់ខ្លួន ។*

### កិច្ចការគ្រូ

គ្រូគួរតែមានគំនិតច្នៃប្រឌិតដោយខ្លួនឯង ក្នុងការរៀបចំនិងផលិតសម្ភារល្បែង និង នាំសិស្សលេងយ៉ាងតិចចំនួនបួន ។ គ្រូគួរតែយកល្បែងរបស់ខ្លួន មកបង្ហាញនៅពេលប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍រៀងរាល់ខែ ដើម្បី ពិភាក្សាជាមួយគ្រូដទៃទៀត ។ ការធ្វើដូចនេះនឹងជួយបង្កើតជាគំនិតល្អៗ ពីគ្រូម្នាក់ទៅគ្រូម្នាក់ទៀត និង ពីសាលារៀនមួយទៅសាលារៀនមួយទៀត ។

ការរៀបចំបង្កើតល្បែងសិក្សានេះ ត្រូវសរសេរល្បែងនោះនៅក្នុងសៀវភៅកំណត់ត្រាគ្រូ ។

## កិច្ចការទី1 : ការបង្កើតល្បែងសិក្សា សម្រាប់គណិតវិទ្យា

-ប្រធានបទ និង ទំព័រសៀវភៅគោល :

-ប្រភេទល្បែង : ផ្គូផ្គង លំដាប់ ចំណែកថ្នាក់

-សម្ភារ : បន្ទះក្ដារ ប័ណ្ណ ផ្សេងៗ ( ... )

-វិធីលេង : បុគ្គល ក្រុមតូច ថ្នាក់ទាំងមូល

**ប្រអប់សរសេរ ឬគូរមុខល្បែង**

<table>
<tr><td>ថ្ងៃខែឆ្នាំ លេងល្បែង :</td><td>កុមារលេង (ចំនួន) :</td></tr>
<tr><td colspan="2"><u>ចម្លើយសិស្ស</u> ( អធិប្បាយពីសមត្ថភាពលេង )</td></tr>
<tr><td colspan="2"><u>ការតាមដានរបស់គ្រូ</u> ( គ្រូអាចសរសេរប្រសិនបើល្បែងត្រូវបានប្រើម្ដងទៀតនៅមុខវិជ្ជា ឬមេរៀនផ្សេង)</td></tr>
</table>

## កិច្ចការទី2 : ការបង្កើតល្បែងសិក្សា សម្រាប់ភាសាខ្មែរ

-ប្រធានបទ និង ទំព័រសៀវភៅគោល :

-ប្រភេទល្បែង : ផ្គូផ្គង លំដាប់ ចំណែកថ្នាក់

-សម្ភារ : បន្ទះក្ដារ ប័ណ្ណ ផ្សេងៗ ( ... )

-វិធីលេង : បុគ្គល ក្រុមតូច ថ្នាក់ទាំងមូល

**ប្រអប់សរសេរ ឬគូរមុខល្បែង**

<table>
<tr><td>ថ្ងៃខែឆ្នាំ លេងល្បែង :</td><td>កុមារលេង (ចំនួន) :</td></tr>
<tr><td colspan="2"><u>ចម្លើយសិស្ស</u> ( អធិប្បាយពីសមត្ថភាពលេង )</td></tr>
<tr><td colspan="2"><u>ការតាមដានរបស់គ្រូ</u> ( គ្រូអាចសរសេរប្រសិនបើល្បែងត្រូវបានប្រើម្តងទៀតនៅមុខវិជ្ជា ឬមេរៀនផ្សេង)</td></tr>
</table>

# កិច្ចការទី3 : ការបង្កើតល្បែងសិក្សា សម្រាប់សិក្សាសង្គម

-ប្រធានបទ និង ទំព័រសៀវភៅគោល :

-ប្រភេទល្បែង : ផ្គូផ្គង លំដាប់ ចំណែកថ្នាក់

-សម្ភារ : បន្ទះក្តារ ប័ណ្ណ ផ្សេងៗ ( ... )

-វិធីលេង : បុគ្គល ក្រុមតូច ថ្នាក់ទាំងមូល

**ប្រអប់សរសេរ ឬគូរមុខល្បែង**

| | |
|---|---|
| **ថ្ងៃខែឆ្នាំ លេងល្បែង :** | **កុមារលេង ( ចំនួន) :** |
| **ចម្លើយសិស្ស** ( អធិប្បាយពីសមត្ថភាពលេង ) | |
| **ការតាមដានរបស់គ្រូ** ( គ្រូអាចសរសេរប្រសិនបើល្បែងត្រូវបានប្រើម្តងទៀតនៅមុខវិជ្ជា ឬមេរៀនផ្សេង) | |

# កិច្ចការទី4 : ការបង្កើតល្បែងសិក្សា សម្រាប់វិទ្យាសាស្ត្រអនុវត្ត

-ប្រធានបទ និង ទំព័រសៀវភៅគោល :

-ប្រភេទល្បែង : ផ្គូផ្គង លំដាប់ ចំណែកថ្នាក់

-សម្ភារ : បន្ទះក្ដារ ប័ណ្ណ ផ្សេងៗ ( ... )

-វិធីលេង : បុគ្គល ក្រុមតូច ថ្នាក់ទាំងមូល

**ប្រអប់សរសេរ ឬគូរមុខល្បែង**

| **ថ្ងៃខែឆ្នាំ លេងល្បែង :** | **កុមារលេង ( ចំនួន) :** |
|---|---|
| **<u>ចម្លើយសិស្ស</u>** ( អធិប្បាយពីសមត្ថភាពលេង ) | |
| **<u>ការតាមដានរបស់គ្រូ</u>** ( គ្រូអាចសរសេរប្រសិនបើល្បែងត្រូវបានប្រើម្ដងទៀតនៅមុខវិជ្ជា ឬមេរៀនផ្សេង) | |

## ៩.ប្រធានបទទី៩ : ការប្រើធនធានសំបូរបែបក្នុងថ្នាក់រៀន

### ព័ត៌មានសម្រាប់គ្រូ

គ្រូ គឺជាអ្នកគ្រប់គ្រងថ្នាក់រៀន ។ ការទទួលខុសត្រូវរបស់គ្រូ គឺត្រូវធ្វើការងារជាមួយកុមារ ដើម្បីបង្កើតបរិស្ថានសិក្សា**សំបូរបែប** ។ នេះមានន័យថា ថ្នាក់រៀនគួរតែផ្តល់នូវសុខភាពល្អ (ស្អាត) ជាកន្លែងទាក់ទាញ និងលើកទឹកចិត្ត។ គោលបំណង គឺដើម្បីឱ្យកុមារមានភាពរីករាយមកកាន់ថ្នាក់រៀនរៀងរាល់ថ្ងៃ និងអាចរកវត្ថុថ្មីៗសម្រាប់មើល និងស្វែងយល់។

បរិស្ថានសិក្សាសំបូរបែបពុំមែនមានន័យថា គ្រូត្រូវតែចំណាយប្រាក់យ៉ាងច្រើនលើការតុបតែងថ្នាក់រៀននោះឡើយ ។ បន្ទប់រៀនគួរតែមានសម្ភារ " សំបូរបែប " សម្រាប់ទាក់ទាញទឹកចិត្ត ។ សម្ភារទាំងនោះ ខ្លះអាចទិញ ដោយប្រើប្រាក់ PAP *(ឧទាហរណ៍: តារាងអក្ខរក្រម ស្រៈ លេខ ឬផែនទី ប្រតិទិន ...)* សម្ភារខ្លះផ្តល់ដោយក្រសួងអប់រំ យុវជន និង កីឡា ឬកម្មវិធីផ្សេងៗ *(ឧទាហរណ៍: ការអប់រំអំពីមីន ជំងឺអេដស៍ ជំងឺគ្រុនផ្តាសាយបក្សី អាហារូបត្ថម្ភ ការអប់រំសម្រាប់ទាំងអស់គ្នា ...)* និងសម្ភារខ្លះទៀត អាចរៀបចំដោយគ្រូ និងសិស្សដូចជា :

- ការដាក់តាំងបង្ហាញស្នាដៃសិស្ស មានអត្ថបទសំណេរ គំនូរ ឬ ហត្ថកម្ម ...
- ឧបករណ៍សម្រាប់ប្រើប្រាស់នៅក្នុងមូលដ្ឋាន ( ទ្រូ កន្ត្រក ...)
- សម្ភារពីបរិស្ថាន មាន ស្លឹក ផ្កា ផ្លែ សត្វល្អិត ...
- ការពិសោធងាយៗសម្រាប់សិស្សសង្កេតមើល និងចងក្រងឯកសារ( ការបណ្តុះគ្រាប់ ឬការដាំរុក្ខជាតិនៅក្នុងទឹក ឬ ក្នុងថូ វដ្តកង្កែប កន្លែងដាក់សត្វល្អិត ផ្លែឈើខូច ...)

គ្រូគួរតែស្វែងរកធនធានគ្រប់ទីកន្លែង ។ ជារឿយៗ ទស្សនាវដ្តី និងកាសែតចាស់ៗ មានភាពគួរឱ្យចាប់អារម្មណ៍ ។ ប័ណ្ណផ្សព្វផ្សាយចាស់ៗដែលឈប់ប្រើ និងព្រឹត្តិការណ៍នានា ឬយុទ្ធនាការលើកកំពស់ការយល់ដឹងរបស់រដ្ឋ អាចជាប្រភពរូបភាព គួរឱ្យចាប់អារម្មណ៍ ជាប្រភពអត្ថបទត្រឹមត្រូវសម្រាប់ការពិភាក្សា និងវិភាគ ។ គ្រូអាចធ្វើការងារជាមួយសិស្សដើម្បីផ្តល់តម្លៃទៅឱ្យប័ណ្ណផ្សព្វផ្សាយ និងតារាងចាស់ៗ ដោយការដាក់ចំណងជើង និង ឈ្មោះ ។ល។

គ្រូ និងកុមារមិនគួរគិតត្រឹមតែពីការរៀបចំដាក់តាំងនោះឡើយ ។ សម្ភារទាំងនោះអាចប្រើធ្វើជាមធ្យោបាយបង្រៀន និងរៀន ។ បន្ទាប់ពីប្រើវាមួយខែ ឬ ពីរខែមក គ្រូគួរតែប្តូរវា ដើម្បីបង្កើនចំណាប់អារម្មណ៍របស់កុមារ។

### ការប្រើប័ណ្ណផ្សព្វផ្សាយសម្រាប់ការបង្រៀន និង រៀន

ប័ណ្ណផ្សព្វផ្សាយដែលមានរូបភាព ឬអត្ថបទជាសម្ភារជំនួយយ៉ាងមានសារសំខាន់ក្នុងការបង្រៀន ។ វាងាយស្រួលចំពោះគ្រូក្នុងការបង្កើតសំណួរ ដែលផ្តល់ឱកាសដល់កុមារបានហាត់នូវបំណិនស្តាប់ និងនិយាយ។ សំណួរអាចសួរនូវកម្រិតខុសៗគ្នា ដូចមាននៅក្នុងឧទាហរណ៍ខាងក្រោម :

| សំណួរ | ចម្លើយ | កម្រិតសំណួរ |
|---|---|---|
| តើប្អូនៗឃើញអ្វីខ្លះនៅក្នុងរូបភាព? | ខ្ញុំអាចមើលឃើញ ... | ការចងចាំ |
| តើប័ណ្ណផ្សព្វផ្សាយនេះនិយាយអំពីអ្វី? | និយាយអំពី ... | យល់ដឹង |
| ហេតុអ្វីក៏ប្អូនគិត...? | ខ្ញុំគិត...ពីព្រោះ... | ពិចារណាហ្មត់ចត់ |
| តើប្អូនចូលចិត្តអ្វីជាងគេអំពី ...? | ខ្ញុំចូលចិត្ត... ពីព្រោះ ... | ពិចារណាហ្មត់ចត់ |

គ្រូក៏អាចប្រើប័ណ្ណផ្សព្វផ្សាយផងដែរ សម្រាប់ធ្វើជាល្បែងសិក្សាងាយៗ ដូចជា:

- តើប្អូនមើលឃើញអ្វីខ្លះនៅក្នុងប័ណ្ណផ្សព្វផ្សាយដែលចាប់ផ្ដើមដោយអក្សរ ...?
- តើប្អូនអាចបិទស្លាកសញ្ញាសរសេរនេះនៅខាងស្ដាំ លើប័ណ្ណផ្សព្វផ្សាយឬទេ ?
- តើអ្វីទៅដែលជាវត្ថុធំជាងគេប្រាំ ដែលប្អូនអាចមើលឃើញនៅក្នុងប័ណ្ណផ្សព្វផ្សាយ ? ចូរបិទលេខទាំងនេះ (១, ២, ៣, ៤ និង ៥ ) នៅលើវត្ថុដែលប្អូនរកឃើញ ។
- តើមានវត្ថុអ្វីខ្លះនៅក្នុងប័ណ្ណផ្សព្វផ្សាយដែលមានពិណ៌បៃតង ក្រហម ស ...?
- តើពួកគេកំពុងសន្ទនាអំពីអ្វី នៅក្នុងប័ណ្ណផ្សព្វផ្សាយនេះ ?(ដើរតួ ការនិយាយដោយប្រើ  )

ល្បែងសិក្សាទាំងនេះមានសារសំខាន់សម្រាប់ផ្ដល់ជាកិច្ចការឱ្យសិស្សធ្វើ ប្រសិនបើពួកគេបញ្ចប់មេរៀនមុនពេល ឬប្រសិន បើកុមារមួយចំនួនបញ្ចប់កិច្ចការមុនកុមារដទៃទៀត ។

## ការប្រើប្រាស់ផែនទីសម្រាប់ការបង្រៀននិងរៀន

ផែនទីគឺជាវត្ថុជំនួយ យ៉ាងសំខាន់ក្នុងការបង្រៀននិងរៀន ។ គ្រូអាចប្រើផែនទីធ្វើជាធនធានឱ្យសិស្សរៀនភាសាខ្មែរ គណិតវិទ្យា និងសិក្សាសង្គម ។ នៅពេលកុមារកាន់តែធំ គំនិត ចំណេះដឹង និងបទពិសោធ ពួកគេក៏កាន់តែអភិវឌ្ឍ។ នៅថ្នាក់ទី១ កុមារផ្ដោតទៅលើខ្លួនឯង គ្រួសារ និងផ្ទះ ។ នៅថ្នាក់ទី២ និងទី៣ សិស្សចាប់ផ្ដើមគិត និងរៀនអំពីភូមិ ឃុំ និងស្រុករបស់ខ្លួន។ នៅថ្នាក់ខ្ពស់ជាងនេះ សិស្សរៀនអំពីខេត្ត ប្រទេស តំបន់របស់ខ្លួន និងពិភពលោក ។

| ថ្នាក់ទី | ការផ្ដោតរបស់កុមារ | ផែនទី |
|---|---|---|
| ១ | ផ្ទះខ្ញុំ សាលារៀនខ្ញុំ | បន្ទប់រៀន ភូមិ |
| ២ | ភូមិ ឃុំ/សង្កាត់ | តំបន់មូលដ្ឋាន |
| ៣ | ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុងខ្ញុំ | ស្រុក/ខណ្ឌ ខេត្ត/ក្រុង |
| ៤ | ខេត្ត/ក្រុង ប្រទេសខ្ញុំ | ខេត្ត ប្រទេសកម្ពុជា |
| ៥ | ប្រទេសខ្ញុំ តំបន់ខ្ញុំ ពិភពលោក | ប្រទេស តំបន់អាស៊ីភាគអាគ្នេយ៍ ពិភពលោក |
| ៦ | ពិភពលោក | ប្រទេស តំបន់អាស៊ីភាគអាគ្នេយ៍ ពិភពលោក |

គ្រូបង្រៀនអាចប្រើគំនិតជាច្រើនដែលធ្វើឱ្យកុមារផ្តល់ចម្លើយដើម្បីប្រើប្រាស់ផែនទីមួយ ។ ឧទាហរណ៍ ៖ គ្រូអាចសួរសំណួរផ្សេងៗទៀតអំពីឈ្មោះ ទីតាំង (ទិសខាងជើង ត្បូង កើត លិច ) ផ្ទៃក្រឡា ចម្ងាយ ទន្លេ ភ្នំ បឹង សមុទ្រ ព្រំប្រទល់ និងប្រទេសជិតខាង ។

ការប្រើប្រាស់ប័ណ្ណផ្សព្វផ្សាយ និងផែនទីជាសម្ភារឧបទេសក្នុងការចោទសួរអំពីសម្ភារទាំងនោះ ហើយជាវិធីដ៏ល្អសម្រាប់សិស្សអនុវត្តនូវបំណិនស្តាប់ ។ គ្រូបង្រៀនអាចជួយសិស្សឱ្យមានការរីកចម្រើននូវបំណិននិយាយ ដោយសួរសំណួរដល់ពួកគេដើម្បីពន្យល់នូវមូលហេតុហេតុអ្វីបានជាគេឱ្យចម្លើយបែបនេះ ?

## កិច្ចការគ្រូ

### កិច្ចការទី 1 ៖ ការប្រើប័ណ្ណផ្សព្វផ្សាយសម្រាប់បង្រៀន

គ្រូធ្វើផែនការនិងដឹកនាំសកម្មភាពរៀនសូត្ររបស់សិស្ស ដោយផ្អែកលើប័ណ្ណផ្សព្វផ្សាយពីរ ឬតារាងពីរដែលមាននៅក្នុងបន្ទប់រៀន ។ គ្រូសរសេរប្រភេទប័ណ្ណផ្សព្វផ្សាយដែលគាត់ប្រើ និងសកម្មភាពរៀនសូត្រ ដែលគាត់ធ្វើជាមួយកុមារនៅលើសន្លឹកកិច្ចការក្នុងតារាងខាងក្រោម ។

### កិច្ចការទី 2 ៖ ការប្រើផែនទីសម្រាប់បង្រៀន

គ្រូប្រើផែនទីដែលសមស្របទៅនឹងកម្រិតថ្នាក់របស់ថ្នាក់គាត់( *ខ្ចីមកពីបណ្ណាល័យ បន្ទប់ធនធាន ឬពីគ្រូម្នាក់ទៀត ប្រសិនបើគាត់ពុំមានផែនទីនៅក្នុងបន្ទប់រៀនរបស់ខ្លួន*) ។ គ្រូបង្កើតសកម្មភាពរៀនសូត្រខុសៗគ្នាប្រាំ ដោយប្រើផែនទីធ្វើជាធនធានសម្រាប់ការបង្រៀន និងរៀន។ សកម្មភាពទាំងនេះ អាចបញ្ចូលទៅក្នុងមេរៀនធម្មតា តាមកាលវិភាគ ឬបង្រៀនជាសកម្មភាពសង្ខេបនៅពេលកុមារបានបញ្ចប់ការងារសំខាន់ៗរបស់ពួកគេ ។ គ្រូសរសេររៀបរាប់ពីសកម្មភាពរៀនសូត្រ ដែលពួកគាត់បានធ្វើផែនការ និងបង្រៀននៅលើសន្លឹកកិច្ចការក្នុងតារាងទំព័របន្ទាប់ ។

**កិច្ចការទី 1 ៖ ការប្រើប័ណ្ណផ្សព្វផ្សាយ/តារាង**

| ប្រភេទប័ណ្ណផ្សព្វផ្សាយ | ការរៀបរាប់អំពីសកម្មភាពរៀនសូត្រ |
|---|---|
| ១. | |
| ២. | |

# កិច្ចការទី 2 : ការប្រើផែនទី

| ប្រភេទផែនទី |
|---|
| ការរៀបរាប់អំពីសកម្មភាពរៀនសូត្រទី ១ |
| ការរៀបរាប់អំពីសកម្មភាពរៀនសូត្រទី ២ |
| ការរៀបរាប់អំពីសកម្មភាពរៀនសូត្រទី ៣ |
| ការរៀបរាប់អំពីសកម្មភាពរៀនសូត្រទី ៤ |
| ការរៀបរាប់អំពីសកម្មភាពរៀនសូត្រទី ៥ |

## ៥.ប្រធានបទទី៥ ៖ ការអភិវឌ្ឍអំណាន

## ព័ត៌មានសម្រាប់គ្រូ

***សម្គាល់*** ៖ *ពាក្យ "អត្ថបទ" ត្រូវបានប្រើនៅក្នុងប្រធានបទនេះ ពីព្រោះគេត្រូវការពាក្យទូទៅមួយ ដើម្បីពណ៌នាភាសា សរសេរ ដែលមានប្រភេទខុសៗគ្នាទាំងអស់ ។ អត្ថបទជាច្រើនដែលកុមារអាន ភាគច្រើនជា "រឿងនិទាន" ។ ប៉ុន្តែជាការសំខាន់ក៏ត្រូវឱ្យកុមារអានអត្ថបទផ្សេងៗទៀតដែរ ដូចជា ៖ ការពន្យល់ ការណែនាំ ការបញ្ជា និង ការផ្សាយពាណិជ្ជកម្ម... ។*

គ្រូជាច្រើនបារម្ភថា កុមារអភិវឌ្ឍសមត្ថភាពអាន និងសរសេរយឺតណាស់ ។ គ្រូបង្រៀននៅថ្នាក់ខ្ពស់តួញត្អែរថា កុមារចូលមករៀននៅក្នុងថ្នាក់របស់គាត់ខ្សោយមុខវិជ្ជាភាសាខ្មែរ ។ មូលហេតុមួយចំនួនចំពោះរឿងនេះ គឺកុមារជាច្រើនធំធាត់នៅក្នុងស្ថានភាពគ្រួសារដែលពុំមានសៀវភៅ ទស្សនាវដ្ដី ឬកាសែតច្រើនគ្រប់គ្រាន់ទេ ។ ជារឿយៗកុមារពុំដែលឃើញរៀមច្បង ឬមនុស្សចាស់អានឡើយ ។ នេះមានន័យថា កុមារជាច្រើនមករៀនដោយខ្វះការយល់ដឹងជាមូលដ្ឋានអំពីអក្សរ ឬ ចំណេះដឹងអំពីភាពប្លែកៗគ្នា នៃគោលបំណងរបស់អត្ថបទផ្សេងៗ ។

**ក្បួនខ្នាតនៃការអានអត្ថបទ (**Conventions of print **)**

មុននឹងកុមារចេះអានដោយខ្លួនឯង គ្រូអាចជួយពួកគេឱ្យរៀនខ្លះៗ នូវក្បួនខ្នាតជាមូលដ្ឋាន អំពីការអានតាមរយៈការបង្ហាញ និងនិយាយ ។ ក្បួនខ្នាតទាំងនេះត្រូវបានអ្នកអប់រំហៅថារបៀបអានអក្សរ ។ ជាក់ស្ដែងរបៀបអានអក្សរខ្លះមានភាពងាយដែលធ្វើឱ្យគ្រូអាចភ្លេចពីការលំបាកនៃការអានរបស់កុមារ ។ ឧទាហរណ៍ របៀបអានអត្ថបទគឺ ៖

- ត្រូវអានអត្ថបទ តាមលំដាប់ទំព័រនៃសៀវភៅ
- ត្រូវចាប់ផ្ដើមអានពីផ្នែកខាងលើនៃទំព័រ
- ត្រូវអានអត្ថបទ ពីឆ្វេងទៅស្ដាំតាមបន្ទាត់នីមួយៗ
- ត្រូវអានដោយពុំមានការដកឃ្លាឡើយ នៅចន្លោះពាក្យជាច្រើន
- ត្រូវអានដោយមានការដកឃ្លានៅចន្លោះឃ្លាខ្លះ អនុប្រយោគខ្លះ និងចំពោះប្រយោគនានា
- ត្រូវអានដោយមានការគោរពទៅតាមសញ្ញាសម្ព័ន្ធនៃភាសាខ្មែរ

របៀបអានអក្សរចំពោះភាសាទាំងអស់ ពុំមានភាពដូចគ្នាឡើយ ។

អំណានឮៗរបស់គ្រូ គឺជាវិធីដ៏ល្អមួយសម្រាប់សិស្សានុសិស្សអនុវត្តបាននូវសមត្ថភាពស្ដាប់ប៉ុន្តែការអានឮៗអាចជួយសិស្សផងដែរដើម្បីយល់បានអំពីរបៀបអានដែលជាគ្រឹះនៃក្បួនខ្នាតក្នុងការអាន ។ គ្រូអាចប្រើប្រាស់នូវវិធីងាយៗខ្លះនៅពេលដែលគេអានអត្ថបទឮៗ ។ វិធីបង្រៀនបែបនេះ សមស្របទៅនឹងកម្រិតថ្នាក់ទី១ ទី២ និងសិស្សថ្នាក់ទី៣ខ្លះៗដែលពួកគេពុំទាន់មានសមត្ថភាពអាន ។

**វិធីងាយៗខ្លះ  ដែលគ្រូអាចប្រើដើម្បីជួយកុមារឱ្យរៀនអាន  :**

- មុននឹងអានគ្រូត្រូវបង្ហាញរូបភាព រួចសួរសិស្សឱ្យទស្សន៍ទាយថា តើអត្ថបទនេះនិយាយអំពីអ្វី ?
- គ្រូអានអត្ថបទនៅលើកទីមួយ ដោយគ្រាន់តែឱ្យសិស្សស្តាប់ប៉ុណ្ណោះ
- បន្ទាប់មកគ្រូអានអត្ថបទ ដោយកាន់សៀវភៅលើកឡើង ដើម្បីឱ្យកុមារទាំងអស់អាចមើលឃើញ
- ពេលគ្រូអាន គាត់យកម្រាមដៃចង្អុលអត្ថបទពីឆ្វេងទៅស្តាំ
- នៅពេលគ្រូអានចប់មួយបន្ទាត់ គាត់ត្រូវមើល/ចង្អុលទៅបន្ទាត់បន្ទាប់ និង ត្រូវចាប់ផ្តើមពីខាងឆ្វេង
- គ្រូប្រាប់កុមារឱ្យអានអត្ថបទ តាមនៅក្នុងសៀវភៅពួកគេ ដោយប្រើម្រាមដៃពួកគេចង្អុលតាម នៅពេលដែលគ្រូអាន
- គ្រូត្រូវឈរនៅកន្លែងខុសៗគ្នាក្នុងបន្ទប់ នៅពេលដែលគាត់អាន ដើម្បីសង្កេតមើលថា តើកុមារអានតាមឬទេ
- យូរៗម្តង គ្រូត្រូវឈប់អាននិងសួរសិស្សឱ្យទស្សន៍ទាយពាក្យ ឬ ព្រឹត្តិការណ៍ដែលកើតមានបន្ទាប់ ដែលពួកគេយល់អត្ថន័យ នៅក្នុងសាច់រឿង ឬអត្ថបទ
- ពេលដែលសិស្សមានទំនុកចិត្តហើយ គ្រូអាចឱ្យគេអានអត្ថបទខ្លះៗ ឬអត្ថបទទាំងស្រុង ។ គ្រូអាចចូលរួមម្តងទៀត ប្រសិនបើសិស្សលំបាកក្នុងអំណានរបស់គេ ។

**ការជួយកុមារឱ្យយល់អំពីអ្វីដែលធ្វើឱ្យអត្ថបទ "ពេញលេញ"**

នៅពេលបង្រៀនអំណាន គ្រូភាគច្រើនបានផ្តោតយ៉ាងខ្លាំងទៅលើអក្សរ និង ពាក្យជាជាងទៅលើអត្ថបទទាំងមូល។ លទ្ធផលដែលទទួលបាន គឺកុមារពុំមានឱកាសច្រើនឡើយក្នុងការគិតពិចារណាអំពីអត្ថន័យ និងអ្វីដែលធ្វើឱ្យអត្ថបទ "ពេញលេញ"។ វាជាការលំបាកចំពោះកុមារ ដើម្បីឱ្យមានភាពប៉ិនប្រសប់ក្នុងការអាននិងសរសេរ ប្រសិនបើពួកគេពុំមានឱកាសគិតពិចារណា អំពីអត្ថបទទាំងមូល ។ ទោះបីជាកុមារតូចៗ ក៏អាចរៀនវិភាគអត្ថបទតាមវិធីងាយៗបានដែរ ប្រសិនបើគ្រូសួរសំណួរសមស្រប ។ កុមារនឹងទទួលបានអត្ថប្រយោជន៍ជាច្រើននៅឆ្នាំបន្តបន្ទាប់ ពីការយល់ដឹងទាំងនេះ នៅពេលពួកគេចាប់ផ្តើមសរសេរអត្ថបទខ្លួនឯង ។

នៅពេលគ្រូ និងកុមារបានបញ្ចប់ការអាន គ្រូគួរតែសួរសំណួរដល់កុមារអំពីអត្ថបទទាំងមូល ។ នេះ គឺជាឧទាហរណ៍ខ្លះៗនៃសំណួរដែលអាចជួយកុមារឱ្យអភិវឌ្ឍបញ្ញាញាណរបស់ពួកគេអំពីអ្វី ដែលជាអត្ថបទពេញលេញ :

- តើនរណាជាតួអង្គសំខាន់ជាងគេនៅក្នុងអត្ថបទ ?
- តើមានអ្វីកើតឡើងនៅក្នុងអត្ថបទ ( ព្រឹត្តិការណ៍សំខាន់) ?
- តើព្រឹត្តិការណ៍នៅក្នុងអត្ថបទកើតឡើងនៅកន្លែងណា ?
- តើព្រឹត្តិការណ៍នៅក្នុងអត្ថបទកើតឡើងនៅពេលណា ?
- តើព្រឹត្តិការណ៍ចាប់ផ្តើមយ៉ាងដូចម្តេច ?
- តើអ្វីដែលកើតឡើងបន្ទាប់មកទៀត ... (ហៅកុមារឱ្យនិទានរឿងឡើងវិញដោយប្រើពាក្យពេចន៍ពួកគេ)?
- តើមានអ្វីកើតឡើងនៅចុងបញ្ចប់ ?

| សំណួរគ្រូ | លក្ខណៈនៃអត្ថបទពេញលេញ |
| --- | --- |
| តើនរណាជាតួអង្គសំខាន់ជាងគេនៅក្នុងអត្ថបទ ? | តួអង្គ |
| តើមានអ្វីកើតឡើងនៅក្នុងអត្ថបទ ?(សកម្មភាពសំខាន់) | ព្រឹត្តិការណ៍ |
| តើព្រឹត្តិការណ៍នៅក្នុងអត្ថបទកើតឡើងនៅកន្លែងណា ? | ទីកន្លែង |
| តើព្រឹត្តិការណ៍នៅក្នុងអត្ថបទកើតឡើងនៅពេលណា ? | ពេលវេលា |
| តើវាចាប់ផ្ដើមយ៉ាងដូចម្ដេច ? | សេចក្ដីផ្ដើម |
| តើអ្វីដែលកើតឡើងបន្ទាប់មកទៀត ?(ហៅសិស្សឱ្យនិទានរឿងឡើងវិញ ដោយប្រើពាក្យពេចន៍សិស្ស) | តួសេចក្ដីនៃអត្ថបទ រឿងនិទាន |
| តើមានអ្វីកើតឡើងនៅចុងបញ្ចប់ ? | សេចក្ដីសន្និដ្ឋាន |
| តើផ្នែកណានៃអត្ថបទដែលប្អូនចូលចិត្ត ? ហេតុអ្វី ? | ជំរុញការពិចារណាហ្មត់ចត់ |
| តើនរណាជាតួអង្គក្នុងអត្ថបទដែលអ្នកចូលចិត្ត ? ហេតុអ្វី ? | ជំរុញការពិចារណាហ្មត់ចត់ |

## អត្ថបទជាក់ស្ដែង (សម្រាប់សិស្សធំៗ)

សិស្សភាគច្រើនបានត្រឹមតែអានអត្ថបទដែលមាននៅក្នុងសៀវភៅអាន ឬនៅក្នុង "សៀវភៅរឿង" ពីបណ្ណាល័យប៉ុណ្ណោះ ។ គ្រូអាចជួយពង្រីកបទពិសោធរបស់សិស្សឱ្យក្លាយជាអ្នកអាន ដោយណែនាំគេឱ្យស្គាល់អត្ថបទប្រភេទដទៃទៀត ។ អត្ថបទទាំងនោះភាគច្រើន និយាយអំពីជីវិតប្រចាំថ្ងៃដូចជា អត្ថបទផ្សាយពាណិជ្ជកម្ម និង ផលិតផល ("ប្រទេសខ្ញុំស្រាបៀរខ្ញុំ") (សារធាតុគីមីផ្សំនៅក្នុងកំប៉ុងភេសជ្ជៈ) ។ អត្ថបទទាំងនេះកម្រប្រើសម្រាប់ការសិក្សាណាស់ ។ លើសពីនេះទៀត ដើម្បីអាននិងយល់ន័យនៃអត្ថបទ គ្រូអាចសួរសំណួរដែលជំរុញកុមារឱ្យគិតពិចារណាអំពីមូលហេតុដែលគេសរសេរអត្ថបទទាំងនេះ (**គោលបំណង**) និងអ្នកអាន (**ទស្សនិកជន**) ។

| ប្រភេទអត្ថបទជាក់ស្ដែង | គោលបំណង | ទស្សនិកជន |
| --- | --- | --- |
| ផ្សាយពាណិជ្ជកម្ម | ដើម្បីលក់ផលិតផល | អ្នកចូលចិត្តទិញផលិតផល |
| ការណែនាំ ពីរបៀបប្រើ | បង្ការការខូចខាត ប្រើប្រាស់មានប្រសិទ្ធភាព | អ្នកទិញ |
| រូបមន្តធ្វើម្ហូប | បង្ហាញរបៀបធ្វើម្ហូប | អ្នកចង់ដាំស្ល របស់នោះ |
| ព័ត៌មានពីការបោះឆ្នោត | -ទាក់ទាញមនុស្សឱ្យបោះឆ្នោត<br>-ចេះរបៀបបោះឆ្នោត | អ្នកដែលអាចបោះឆ្នោតបាន |
| ព័ត៌មានពីសុខភាព | ថែទាំសុខភាពល្អ | អ្នកដែលចាប់អារម្មណ៍ពីសុខភាពអនាម័យ |

# កិច្ចការគ្រូ

## កិច្ចការទី 1 ៖ ការវិភាគអត្ថបទជាមួយកុមារ

គ្រូជ្រើសរើសអត្ថបទមួយ (ចេញពីសៀវភៅមុខវិជ្ជាភាសាខ្មែរ ឬ សៀវភៅរឿងពីបណ្ណាល័យ) ។ ជាដំបូងគ្រូអានអត្ថបទទាំងមូលឱ្យសិស្សស្តាប់ ។ បន្ទាប់មកគ្រូអានឡើងវិញម្តងទៀតយឺតៗ បង្ហាញ និង និយាយអំពីរូបភាពខ្លឹមសារពាក្យសំខាន់ៗដែលអាចជាពាក្យថ្មី ។

បន្ទាប់មកទៀតគ្រូសួរកុមារ នូវសំណួរជាបន្តបន្ទាប់អំពីអត្ថបទ ។ ប្រសិនបើកុមារដឹងចម្លើយភ្លាមៗ គ្រូសួរសំណួរបន្ទាប់ ។ ប្រសិនបើកុមារពុំប្រាកដទេនោះគ្រូត្រូវត្រឡប់មករកសៀវភៅវិញ និងព្យាយាមរកផ្នែកអត្ថបទដែលជាចម្លើយនៃសំណួរនោះជាមួយកុមារ ។

បន្ទាប់ពីបញ្ចប់សកម្មភាពនេះហើយ គ្រូកត់ត្រាចម្លើយកុមារនៅលើសន្លឹកកិច្ចការ (ទំព័របន្ទាប់) ។

## កិច្ចការទី 2 ៖ គ្រូស្រាវជ្រាវអំពីអំណានរបស់កុមារ

ចំពោះកិច្ចការអំនានទី២ គ្រូត្រូវធ្វើសម្ភាសន៍ខ្លីៗ ជាមួយកុមារប្រាំមួយនាក់ (កុមារីពនាក់ កុមារា៣នាក់) នៅក្នុងថ្នាក់គាត់នឹងសួរពួកគេអំពីប្រភេទរឿងនិទានដែលពួកគេចូលចិត្តអានជាងគេ ។ គ្រូគួរតែព្យាយាមដើម្បីទទួលបានចម្លើយបីខុសៗគ្នាពីកុមារម្នាក់ៗ ប៉ុន្តែត្រូវទទួលយកចម្លើយមួយ ប្រសិនបើជាចម្លើយតែមួយគត់របស់កុមារ ។

ការសម្ភាសន៍នេះ មិនគួរធ្វើក្នុងម៉ោងបង្រៀនឡើយ ។ គ្រូគួរតែព្យាយាមនិយាយជាមួយកុមារ នៅពេលដែលពួកគេទំនេរ ដូចនេះវានឹងមិនដូចជាកិច្ចការសាលាឡើយ ។ គ្រូអាចនិយាយទៅកាន់សិស្សនៅពេលពួកគេលេងតាមផ្លូវទៅផ្ទះ ឬ នៅកន្លែងក្រៅផ្លូវការដទៃទៀត ។

ត្រូវកត់ត្រាចម្លើយកុមារនៅលើសន្លឹកកិច្ចការ ។ បន្ទាប់ពីធ្វើសម្ភាសន៍បានប្រាំមួយនាក់ហើយគ្រូគួរតែសរសេរប្រភេទរឿងខុសៗគ្នា និងកត់ត្រាពីចំនួនកុមារតាមប្រភេទរឿងនីមួយៗដែលកុមារបានលើកឡើង ។

## កិច្ចការទី1 ៖ ការវិភាគអត្ថបទ

| |
|---|
| **ប្រភពអត្ថបទ** (សៀវភៅអាន ទស្សនាវដ្ដី សៀវភៅរឿង) ៖ |
| **ចំណងជើងអត្ថបទ ៖** |
| **ថ្ងៃខែឆ្នាំ បង្រៀន ៖** |

| សំណួរគ្រូ | ចម្លើយរបស់សិស្ស |
|---|---|
| -តើនរណាជាតួអង្គសំខាន់ជាងគេនៅក្នុងអត្ថបទ ? | |
| -តើមានអ្វីកើតឡើង នៅក្នុងអត្ថបទ (ព្រឹត្តិការណ៍សំខាន់) ? | |
| តើព្រឹត្តិការណ៍នៅក្នុងអត្ថបទ កើតឡើងនៅកន្លែងណា ? | |
| តើព្រឹត្តិការណ៍នៅក្នុងអត្ថបទ កើតឡើងនៅពេលណា ? | |
| តើវាចាប់ផ្ដើមយ៉ាងដូចម្ដេច ? | |
| តើអ្វីដែលកើតឡើងបន្ទាប់មកទៀត (ហៅកុមារឱ្យនិទានរឿងឡើងវិញដោយប្រើពាក្យពេចន៍ពួកគេ) ? | |
| តើមានអ្វីកើតឡើងនៅចុងបញ្ចប់ ? | |

| | |
|---|---|
| តើផ្នែកណានៃអត្ថបទដែលប្អូនចូលចិត្ត ? ហេតុអ្វី ? | |
| តើនរណាជាតួអង្គក្នុងអត្ថបទ ដែលអ្នកចូលចិត្ត ? ហេតុអ្វី ? | |

## កិច្ចការទី2 : គ្រូស្រាវជ្រាវអំពីចំណង់ចំណូលចិត្តរបស់សិស្ស

| ឈ្មោះសិស្ស | អាយុ | ភេទ | ប្រភេទរឿងដែលគេចូលចិត្ត |
|---|---|---|---|
| | | | ១.<br>២.<br>៣. |
| | | | ១.<br>២.<br>៣. |
| | | | ១.<br>២.<br>៣. |
| | | | ១.<br>២.<br>៣. |
| | | | ១.<br>២.<br>៣. |
| | | | ១.<br>២.<br>៣. |

| ថ្នាក់ទី... | |
|---|---|
| ប្រភេទរឿងដែលបានលើកឡើង | ចំនួនសិស្សដែលបានលើកឡើង |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

## ៦.ប្រធានបទទី៦ : ការអភិវឌ្ឍសំណេរ

### ព័ត៌មានសម្រាប់គ្រូ

មនុស្សមួយចំនួនគិតថា "សមត្ថភាពសរសេរ" មានភាពដូចគ្នាទៅនឹង "បំណិនសំណេរដោយដៃ "។ ពួកគេគិតថា ប្រសិនបើគេចេះអក្សរ និងអាចគូសដោយខ្មៅដៃ ឬ ប៊ិកពេលនោះពួកគេ អាចសរសេរវាបាន។

ជាការពិតដែលថា ការរៀនសរសេរអក្សរ និងពាក្យគឺជាផ្នែកយ៉ាងសំខាន់នៃការងាររបស់កុមារនៅថ្នាក់ទី១, ២ និងទី៣ ។ ទោះជាយ៉ាងនេះក៏ដោយមកត្រឹមថ្នាក់ទី៤ កុមារគួរតែចាប់ផ្តើមអភិវឌ្ឍន៍បំណិនដទៃទៀតព្រមទាំងសមត្ថភាពសរសេរឱ្យបានស្អាត និងប្រកបបានត្រឹមត្រូវ ។

ដូច្នេះប្រសិនបើការសរសេរល្អមានន័យលើសពីការសរសេរបានស្អាតដោយដៃ និងប្រកបបានត្រឹមត្រូវ តើវាមានន័យដូចម្តេច ? អ្នកអប់រំភាគច្រើនយល់ស្របថា ***អ្នកសរសេរល្អ អ្នកដែលអាចសរសេរដោយចេះប្រើពាក្យ ឃ្លា ល្បះ ខ្លីមានន័យគ្រប់គ្រាន់ ។***

មានការសិក្សាជាច្រើនអំពីសំណេរក្នុងភាសាផ្សេងៗគ្នានៅជុំវិញពិភពលោក។ ការសិក្សាទាំងនេះយល់ស្របថា :

- វិធីដែលល្អជាងគេបំផុតដើម្បីក្លាយទៅជាអ្នកសរសេរម្នាក់ គឺត្រូវសរសេរអត្ថបទដោយខ្លួនឯងផ្ទាល់
- ការចម្លងសំណេររបស់អ្នកដទៃពុំមែនជាវិធីល្អសម្រាប់បំណិនសំណេរឡើយ លើកលែងតែនៅពេលដែលកុមារនៅក្មេងពេក និងពុំទាន់បានរៀនសរសេរដោយដៃ
- សំណេរ គឺជាលំនាំមួយដែលអ្នកសរសេរត្រូវសរសេរជាច្រើនលើក (សរសេរព្រាងជាច្រើនសា) មុននឹងបញ្ចប់អត្ថបទ
- អ្នកសរសេរអាចទាញផលប្រយោជន៍ពីការពិភាក្សាជាមួយអ្នកដទៃមុននឹងបញ្ចប់អត្ថបទ
- អត្ថបទទាំងឡាយត្រូវចែងចែកជាច្រើនប្រភេទ ហើយប្រភេទនីមួយៗមានលក្ខណៈផ្ទាល់របស់វា
- សិស្សដែលបានយល់ពីមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធ និងលក្ខណៈនៃសំណេរ គឺជាអ្នកសរសេរដ៏ពូកែ ។

### សំណេរដើម

សំណេរដើមសំខាន់ណាស់ សម្រាប់គ្រូក្នុងការផ្តល់ឱកាសដល់កុមារទោះជាគេនៅតូចពេកក៏ដោយ ដើម្បីឱ្យគេសរសេរដោយខ្លួនឯង ។ នេះមានន័យថាសំណេរបានមកពីគំនិតផ្ទាល់ខ្លួនរបស់កុមារ វាពុំមែនត្រូវបានចម្លងពីក្តារខៀន ឬពីសៀវភៅឡើយ ។ កុមារដែលសរសេរសំណេរដើមនឹងកាន់តែមានការជឿជាក់លើខ្លួនឯង ពីព្រោះគេបានអនុវត្តជាក់ស្តែង ល្បះមួយនឹងក្លាយទៅជាពីរ និងបន្ទាប់មកបី និងបន្ទាប់មកទៀតជាកថាខណ្ឌនឹងក្លាយជាអត្ថបទពេញលេញ ។ វាក៏មានសារសំខាន់ដែរ បើគ្រូឱ្យសិស្សមើលគំរូនៃសំណេររបស់គេ ដែលដាក់តាំង ឬ ចងព្យួរលើជញ្ជាំងថ្នាក់រៀន ឬ សំណេរដាក់លើក្តារខៀន។

**អត្ថបទចរចា**

តើសិស្សដែលពុំទាន់ចេះសរសេរនៅឡើយ អាចសរសេរអត្ថបទដោយខ្លួនឯងបានយ៉ាងដូចម្តេច ? ពួកគេអាចធ្វើដូចនេះ តាមរយៈដំណើរការមួយហៅថា "អត្ថបទចរចា"។ នេះមានន័យថា គ្រូនិងសិស្សពិភាក្សា អ្វីដែលសិស្សចង់និយាយនិងនៅពេលដែលសិស្សយល់ស្របហើយ គ្រូត្រូវសរសេរវាឱ្យពួកគេ ។ បន្ទាប់មកគ្រូ និងសិស្សអានអត្ថបទរួមគ្នា ។ ទោះបីជាពួកគេពុំបានសរសេរអត្ថបទនោះដោយខ្លួនឯងក៏ដោយ ក៏កុមារមានអារម្មណ៍ថាជាម្ចាស់អត្ថបទ ពីព្រោះវាជាគំនិតរបស់ពួកគេ ។ ដំណើរការដូចគ្នានេះ អាចប្រើនៅពេលកុមារគូររូបភាព ។ គ្រូអាចសួរនូវអ្វីដែលកុមារចង់សរសេរនៅខាងក្រោមគំនូរ និងបន្ទាប់មកសរសេរនូវអ្វីដែលកុមារនិយាយ ។ អ្នកដែលសរសេរគំនិតរបស់អ្នកដទៃហៅថាអ្នកសរសេរ (Scribe) ។

គ្រូក៏អាចប្រើវិធីអត្ថបទចរចាដោយជោគជ័យ ជាមួយសិស្សថ្នាក់ខ្ពស់នៃសាលាបឋមសិក្សា ។ សិស្សពិភាក្សានៅក្នុងក្រុមអំពីអ្វីដែលពួកគេចង់និយាយ (ការចរចាគ្នា) និងបន្ទាប់មកសមាជិកក្រុមម្នាក់អាចសរសេរគំនិតរបស់ក្រុមទាំងមូល ។

**លំនាំសរសេរ (ការសរសេរព្រាង និងការផ្តល់យោបល់)**

អ្នកសរសេរមួយចំនួនអាចផលិតអត្ថបទល្អឥតខ្ចោះក្នុងរយៈពេលតែមួយលើក ។ សំណេរភាគច្រើនត្រូវតែឆ្លងកាត់ដំណើរការព្រាងមួយ ឬពីរ ឬច្រើនលើកមុននឹងអ្នកសរសេរពេញចិត្ត ។ បច្ចុប្បន្ននេះមានកាងាយស្រួលណាស់ដោយប្រើកុំព្យូទ័រសម្រាប់កែតម្រូវបានគ្រប់ពេល ។ សំណេរដៃវាមានការលំបាកជាង និងមានភាពរាយប៉ាយ ។ ការឆូតចោលការសរសេរបន្ថែម និងការកែប្រែផ្សេងៗទៀតត្រូវធ្វើនៅលើក្រដាស ឬ លើក្តារឆ្នួន ឬ ក្តារខៀន ។ គេមិនគួរិះគន់អ្នកសរសេរចំពោះសំណេរព្រាងដែលគ្មានសណ្តាប់ធ្នាប់ឡើយ ដោយសារការផ្លាស់ប្តូរច្រើនបង្ហាញថាអ្នកសរសេរនោះមានភាពប្រាកដប្រជាអំពីការផលិត **សំណេរព្រាងចុងក្រោយ**ឱ្យមានលក្ខណៈត្រឹមត្រូវ ។

អ្នកសរសេរជាច្រើនទទួលបានអត្ថប្រយោជន៍ពីការដែលមានអ្នកផ្សេងទៀតអាន និងការពិភាក្សា ផ្តល់យោបល់អំពីសេចក្តីព្រាងនៃសំណេររបស់ពួកគេ ។ ការពិភាក្សាផ្តល់យោបល់នេះ អ្នកដែលអានសេចក្តីព្រាងគួរតែផ្តោតជាចម្បងទៅលើអត្ថន័យថា តើវាច្បាស់ឬទេ ? វាច្របូកច្របល់ឬទេ ? តើមានផ្នែកណាដែលអាចធ្វើឱ្យកាន់តែល្អជាងនេះឬទេ ? កំហុសអក្ខរាវិរុទ្ធពុំសូវមានសារសំខាន់ ក្នុងការធ្វើការពិភាក្សាផ្តល់យោបល់ (លុះត្រាតែវាជាអត្ថបទសេចក្តីព្រាងចុងក្រោយ) ។ អត្ថន័យសំណេរចុងក្រោយគួរតែច្បាស់ ហើយរាល់កំហុសទាំងឡាយរួមមាន អក្ខរាវិរុទ្ធ និងសញ្ញាសម្ព័ន្ធត្រូវបានកែតម្រូវ ។

សំណេរព្រាងអាចសរសេរនៅលើក្រដាសចាស់ៗ ឬនៅលើក្តារឆ្នួន ឬលើក្តារខៀនតូចៗ ។ សំណេរព្រាងនៅលើក្តារខៀនតូចៗធ្វើឱ្យការកែតម្រូវមានភាពងាយស្រួល ។ វាក៏ជាការល្អដែរប្រសិនបើក្រុមតូចៗធ្វើការងាររួមគ្នាលើអត្ថបទដោយសារតែពួកគេទាំងអស់អាចនៅជុំគ្នា និងមើលឃើញអត្ថបទរួមគ្នា ។

## កិច្ចការគ្រូ

### កិច្ចការទី១ ៖ អត្ថបទចរចា (សំណេររបស់កុមារ)

ចូរធ្វើការចរចាជាមួយក្រុមសិស្សនៅក្នុងថ្នាក់របស់អ្នកទាក់ទងទៅនឹងមុខវិជ្ជា ឬ មេរៀនអ្វីមួយដែលពួកគេកំពុងតែរៀន ។ ចូរជ្រើសរើសប្រធានបទ/មេរៀនដែលសិស្សមានចំណាប់អារម្មណ៍ ។ គ្រូអាចណែនាំប្រធានបទដោយនិយាយថា :

*ឥឡូវនេះ លោក/អ្នកគ្រូចង់សង្ខេបអំពីអ្វីដែលយើងកំពុងតែសិក្សាក្នុង ... ហើយយើងនឹងផលិតនូវសំណេរមួយរួមគ្នា ។ លោក/អ្នកគ្រូនឹងធ្វើជាអ្នកសរសេរឱ្យប្អូនៗ ប្រសិនបើប្អូនៗអាចប្រាប់លោក/អ្នកគ្រូអំពីប្រធានបទនេះ។ តើយើងចាប់ផ្តើមយ៉ាងដូចម្តេច? តើអ្វីដែលនៅបន្ទាប់? តើមាននរណាចង់បន្ថែមអ្វីផ្សេងទៀតឬទេ...?*

ពេលដែលសិស្សយល់ស្របនូវអ្វីដែលពួកគេចង់និយាយហើយ គ្រូត្រូវសរសេរវានៅលើក្តារខៀន ។ សិស្សអាចប្តូរចិត្ត និង សម្រេចធ្វើការកែប្រែអត្ថបទប្រសិនបើពួកគេចូលចិត្ត ។ នៅពេលសរសេរអត្ថបទទាំងមូល នៅលើក្តារខៀនរួចគ្រូឱ្យសិស្សអានព្រមទាំងជួយឱ្យអានរហូតដល់ចប់ និងសួរពួកគេក្រែងមានអ្វីផ្សេងទៀតដែលគេចង់កែលំអ (បន្ថែម ផ្លាស់ប្តូរ កែតម្រូវ) ។ ត្រូវធ្វើការកែប្រែតាមសំណើ ។ ហៅសិស្សឱ្យផ្តល់ចំណងជើង រួចសរសេរនៅខាងលើអត្ថបទ ។ បន្ទាប់មកកុមារត្រូវចម្លងអត្ថបទចរចាចូលទៅក្នុងសៀវភៅរបស់ខ្លួន ។ គ្រូកត់ត្រាអត្ថបទចូលទៅក្នុងសៀវភៅកំណត់ត្រាគ្រូ ។

<u>**សម្គាល់**</u>: ទំហំអត្ថបទអាស្រ័យទៅលើកម្រិតថ្នាក់ សមត្ថភាពរបស់សិស្ស និងប្រធានបទ ។ សិស្សថ្នាក់ទី១ អាចសរសេរ ៣ ឬ៤ល្បះ ។ ថ្នាក់ទី២និងទី៣ អាចសរសេរ ៥-១០ល្បះ ។ សិស្សធំៗគួរតែសរសេរអត្ថបទកន្លះទំព័រ ។

### កិច្ចការទី២ ៖ សិក្សាករណីដំណើររឿងរបស់សិស្ស (កិច្ចការទី ៦)

នៅក្នុងការសរសេរកិច្ចការនេះ គ្រូគួរតែសរសេរនូវសេចក្តីព្រាងដែលអាចយកទៅប្រជុំជាមួយគ្រូម្នាក់ទៀត ឬជាមួយ គ្រូឧទ្ទេសនៅពេលប្រជុំប្រចាំខែ ។ បន្ទាប់មក គ្រូគួរតែសរសេរសេចក្តីព្រាងមួយទៀតដោយបញ្ចូលនូវគំនិតសុំកែប្រែនៅពេលប្រជុំ និងបង្ហាញសេចក្តីព្រាងចុងក្រោយ ។

## កិច្ចការសំណេរទី១ : អត្ថបទចរចាជាមួយសិស្សនៅក្នុងថ្នាក់ខ្ញុំ

| អត្ថបទចរចា |
|---|
| |
| **ចរចាជាមួយ** : ថ្នាក់ទាំងមូល ក្រុមតូចៗ ផ្សេងទៀត |
| **ថ្ងៃខែឆ្នាំ សំណេរ** : |
| **មុខវិជ្ជា មេរៀននៅក្នុងសៀវភៅសិក្សាគោល** : |

## ៧.ប្រធានបទទី៧ : វង្វាយតម្លៃ និង កម្រងស្នាដៃសិស្ស

### ៧.១ : ប្រភេទនៃការវាយតម្លៃ

#### ព័ត៌មានសម្រាប់គ្រូ

តើគ្រូដឹងបានយ៉ាងដូចម្តេច ថាតើខ្លួនបាន និងកំពុងតែធ្វើការងារជាមួយកុមារ ប្រកបដោយប្រសិទ្ធភាព ឬអត់ ? វិធីមួយក្នុងចំណោមវិធីសំខាន់ៗ **គឺតាមរយៈការវាយតម្លៃ** : វាយតម្លៃពីអ្វីដែលសិស្សបានរៀន និងវាយតម្លៃពីការងាររបស់ខ្លួនក្នុងនាមជាគ្រូ ។ វង្វាយតម្លៃ គឺជាប្រធានបទមួយនៅក្នុងវគ្គបំប៉ន អំពីប្រសិទ្ធភាពនៃការបង្រៀន និងរៀនហើយ នឹងត្រូវដំណើរការពេញមួយឆ្នាំសិក្សា ។ គ្រូនឹងរៀនអំពីប្រភេទនៃការវាយតម្លៃសំខាន់ៗខ្លះ ធ្វើការវាយតម្លៃខ្លះៗលើសិស្ស និងឆ្លុះបញ្ចាំងអំពីការបង្រៀនរបស់ខ្លួនផងដែរ ។

តើគ្រូអាចវាយតម្លៃការរៀនសូត្ររបស់សិស្សតាមវិធីណាខ្លះ ? មានវិធីផ្សេងៗគ្នាជាច្រើនដែលគ្រូនៅជុំវិញពិភពលោក ធ្វើការវាយតម្លៃ ។ វីធីទាំងនេះមាន :

- ការសួរសំណួរ
- ការសង្កេតអត្តចរិតរបស់សិស្ស
- ការសង្កេតមើលការងាររបស់សិស្ស
- ការឱ្យសិស្សពន្យល់បកស្រាយអ្វីមួយ
- ការធ្វើតេស្តផ្ទាល់មាត់ និងតេស្តសរសេរភ្លាមៗ
- ការបង្កើត និងដាក់ពិន្ទុតេស្តសរសេរ
- ..................................................

គ្រូល្អធ្វើការវាយតម្លៃទាំងនេះខ្លះៗ សម្រាប់ជាផ្នែកនៃកិច្ចការប្រចាំថ្ងៃរបស់គាត់ ដូចជាសួរសំណួរ សង្កេតអត្តចរិត និង មើលការងារសិស្ស ។ ការវាយតម្លៃទាំងនេះហៅថា ការវាយតម្លៃ**មិនផ្លូវការ**(INFORMAL) ពីព្រោះវាពុំត្រូវបានគេ ធ្វើផែនការជាមុនឡើយ ហើយវាកើតឡើងគ្រប់ពេល ។ ការរៀបចំ ការធ្វើ និងការដាក់ពិន្ទុ លើការធ្វើតេសជាធម្មតា ហៅថាការវាយតម្លៃ**ផ្លូវការ**(FORMAL)ពីព្រោះគេបានធ្វើផែនការដោយប្រុងប្រយ័ត្ន និង អនុវត្តជាសកម្មភាពពិសេស នៅក្នុងឆ្នាំសិក្សា ។

ប្រភេទនៃការវាយតម្លៃទាំងនេះខ្លះ ត្រូវបានអនុវត្តនៅក្នុងពេលនៃវគ្គសិក្សា ដែលគេហៅថា ការវាយតម្លៃ **តាមដំណាក់**(FORMATIVE) ។ ប្រភេទនៃការវាយតម្លៃដទៃទៀតត្រូវបានគេអនុវត្តនៅដំណាច់វគ្គសិក្សា ដែលគេហៅថា ការវាយតម្លៃ**សរុប**(SUMMATIVE)។ ការវាយតម្លៃតាមដំណាក់មានសារសំខាន់ចំពោះគ្រូនិងសិស្ស ពីព្រោះវាអាចបង្ហាញថាតើសិស្សមានបញ្ហាក្នុងការរៀនសូត្រ ឬគ្មាន ។ បន្ទាប់មកគ្រូ និងសិស្សអាចព្យាយាមដោះស្រាយបញ្ហានោះ។ ប្រសិនបើគេត្រឹមតែធ្វើការវាយតម្លៃសរុប នោះវាអាចមានភាពយឺតយ៉ាវក្នុងការជួយដល់កុមារ ។

គ្រប់ប្រភេទនៃការវាយតម្លៃទាំងអស់ មានសារៈសំខាន់ចំពោះគ្រូ ក្នុងការបង្កើនការយល់ដឹងរបស់គាត់ អំពីភាពរីកចម្រើន ជឿនលឿនក្នុងការរៀនសូត្ររបស់សិស្សម្នាក់ៗនៅក្នុងថ្នាក់ ។ សិស្សទាំងអស់គ្នាត្រូវការការយកចិត្តទុកដាក់ ប៉ុន្តែសិស្ស ជាច្រើនមានការជឿជាក់លើខ្លួនឯង និងមានភាពឯករាជ្យ ។ ពួកគេរៀនយ៉ាងលឿន ហើយរីករាយនឹងរៀនដោយខ្លួនឯង ឬ ជាមួយសិស្សដទៃទៀត ។ សិស្សខ្លះពុំរៀនបានដោយងាយស្រួលឡើយ ហើយត្រូវការការគាំទ្រដោយផ្ទាល់និងការលើកទឹកចិត្តយ៉ាងច្រើនពីគ្រូ ។ គ្រូអាចប្រើការវាយតម្លៃ ដើម្បីរកឱ្យឃើញថា តើសិស្សណាដែលត្រូវការជំនួយបន្ថែម និងជំនួយប្រភេទណាដែលមានសារសំខាន់ជាងគេ ។

វិធីល្អមួយសម្រាប់គ្រូធ្វើការវាយតម្លៃជាពិស្តារលើសិស្សដែលរៀនយឺតគឺតាមរយៈការប្រមូលលទ្ធផលនៃការងាររបស់គេនៅក្នុងឆ្នាំសិក្សា ។ គ្រូប្រៀបធៀបការងាររបស់សិស្ស ពីពេលមួយទៅពេលមួយ និងព្យាយាមធ្វើការសម្រេចចិត្ត :

- តើការងាររបស់សិស្សបង្ហាញភាពជឿនលឿនដែរឬទេ ?
- តើសិស្សមានការរីកចម្រើនលើមុខវិជ្ជាណាខ្លះ និងមិនរីកចម្រើនលើមុខវិជ្ជាណាខ្លះទៀត ?
- ប្រសិនបើពុំមានការរីកចំរើនទេ តើមានបញ្ហាអ្វីដែលកើតឡើងម្តងហើយម្តងទៀតចំពោះកុមារ ?
- តើសកម្មភាពប្រភេទណាខ្លះ ដែលនឹងជួយសិស្សទាំងនេះឱ្យចាប់ផ្តើមរៀនសូត្របានល្អប្រសើរឡើង ?

ឧទាហរណ៍ៈ ប្រសិនបើ សិស្សម្នាក់ពិតជាពុំយល់អំពីរបាប់ចំនួន និងទំនាក់ទំនងរវាង ខ្ទង់រាយ ខ្ទង់ដប់ និង ខ្ទង់រយ នោះពួកគេនឹងមានបញ្ហាជាច្រើននៅក្នុងមុខវិជ្ជាគណិតវិទ្យាបន្ទាប់ពីថ្នាក់ទី២ទៅ។ សិស្សត្រូវតែរៀន ដោយប្រើសម្ភារជាក់ស្តែងម្តងទៀត រហូតដល់ពួកគេបានយល់ច្បាស់លាស់ល្អ ។

នៅក្នុងវគ្គប្រសិទ្ធភាពនៃការបង្រៀន និងរៀន គ្រូនឹងអនុវត្តទម្រង់នៃការវាយតម្លៃផ្សេងៗគ្នា ។ គ្រូនឹងប្រើការវាយតម្លៃ ***មិនផ្លូវការ*** ដើម្បីធ្វើការកំណត់លក្ខណៈរបស់កុមារដែលរៀននៅក្នុងថ្នាក់របស់ពួកគាត់ ។ គ្រូនឹងជ្រើសរើសកុមារប្រាំនាក់ដែលរៀននៅក្នុងឆ្នាំសិក្សា ធ្វើការវាយតម្លៃ***តាមចំណាក់*** ដោយប្រមូលលទ្ធផលនៃការងារសរសេររបស់ពួកគេ និងចងក្រងជា ***កម្រងស្នាដៃសិស្ស*** សម្រាប់សិស្សម្នាក់ៗ ។

***កម្រងស្នាដៃសិស្ស*** គឺជាសឺមីមួយ ដែលមានលទ្ធផលនៃការងាររបស់សិស្សដែលប្រមូលបានក្នុងឆ្នាំសិក្សាដែលគ្រូអាចប្រើ សម្រាប់វាយតម្លៃពីការរៀនសូត្ររបស់ពួកគេ ។ កម្រងស្នាដៃសិស្ស ក៏មានសារប្រយោជន៍យ៉ាងខ្លាំង ចំពោះគ្រូ ដើម្បីចែករំលែកជាមួយមាតាបិតាសិស្ស ដើម្បីបង្ហាញដល់ពួកគាត់នូវលទ្ធផលពិតប្រាកដនៃការរីកចម្រើន ជឿនលឿន ក្នុងការរៀនសូត្រ របស់កូនៗគាត់ក្នុងឆ្នាំសិក្សា ។

## កិច្ចការគ្រូ

ចូរប្រើការវាយតម្លៃមិនផ្លូវផ្លូវការ ( ការសង្កេតអត្តចរិត ស្តាប់ការនិយាយរបស់កុមារ មើលការងារសរសេរពួកគេ) ដើម្បីដឹងអំពីកុមារនៅក្នុងថ្នាក់របស់លោក/លោកស្រី ។ ចូរជ្រើសរើស**សិស្ស ៥នាក់ ដែលម្នាក់ជាអ្នករៀនពូកែ ២នាក់រៀនមធ្យម និង ២នាក់ទៀតជាសិស្សដែលរៀនយឺត** ។ ចូរជ្រើសរើសសិស្សដូចខាងក្រោម :

| សិស្សរៀនពូកែ | សិស្សរៀនមធ្យម | សិស្សរៀនយឺត |
|---|---|---|
| កុមារី ១ | កុមារី ១ កុមារា ១ | កុមារី ១ កុមារា ១ |

**កិច្ចការទី I ៖ កម្រងស្នាដៃសិស្សសម្រាប់វាយតម្លៃ**

ជ្រើសរើសសិស្ស ៥នាក់សម្រាប់ធ្វើការវាយតម្លៃលើកម្រងស្នាដៃសិស្ស (កុមារី ៣នាក់ និងកុមារា២នាក់) ។

រៀបចំកម្រងស្នាដៃសម្រាប់កុមារ ៥នាក់ (កម្រងស្នាដៃសិស្ស គឺជាសឺមីដែលមានឯកសារលំអិតអំពីសិស្សម្នាក់ៗ អំពីលទ្ធផលនៃការងាររបស់គេ និងកំណត់ត្រាខ្លះដែលគ្រូសរសេរ) ។

គ្រូគួរតែសរសេរព័ត៌មានសម្រាប់សិស្សម្នាក់ៗនៅលើសន្លឹកព័ត៌មានសិស្សនីមួយៗ និងដាក់វានៅក្នុងកម្រងស្នាដៃសិស្ស (សូមមើលទំព័របន្ទាប់) ។

**កិច្ចការទី 2 ការប្រមូលកម្រងស្នាដៃសិស្ស I ៖**

កិច្ចការគំរូអំពី ៖ នព្វន្ត សំណេរ គំនូរ ប្រមូលនៅ ខែវិច្ឆិកា ។ ពិភាក្សានៅក្នុងអង្គប្រជុំប្រចាំខែលើកទី ២ (ខែវិច្ឆិកា) ។

**កិច្ចការទី 3 ការប្រមូលកម្រងស្នាដៃសិស្ស 2៖**

កិច្ចការគំរូអំពី ៖ នព្វន្ត សំណេរ គំនូរ ប្រមូលនៅខែកុម្ភៈ ។ ពិភាក្សានៅអង្គប្រជុំប្រចាំខែលើកទី៥ (ខែកុម្ភៈ) ។

**កិច្ចការទី 4 ការប្រមូលកម្រងស្នាដៃសិស្ស 3៖**

កិច្ចការគំរូអំពី ៖ នព្វន្ត សំណេរ គំនូរ ប្រមូលនៅខែមេសា មុនវិស្សមកាលតូច ។ ពិភាក្សានៅអង្គប្រជុំប្រចាំខែលើកទី៧(ខែ មេសា) ។

**កិច្ចការទី 5 ការប្រមូលកម្រងស្នាដៃសិស្ស 4៖**

កិច្ចការគំរូអំពី ៖ នព្វន្ត សំណេរ គំនូរ ប្រមូលនៅខែមិថុនា ។ ពិភាក្សានៅអង្គប្រជុំប្រចាំខែលើកទី៩ (ខែមិថុនា) ។

**កិច្ចការទី ៦៖ សិក្សាករណីដំណើររឿងរបស់កុមារ (សូមមើលខាងក្រោម)**

ចូរសរសេរ អំពីសិក្សាករណីដំណើររឿងរបស់សិស្សម្នាក់ ឬ ពីរនាក់ដែលជាអ្នករៀនយឺត ។ ចូរនាំយកការវិភាគដំណើររឿង នេះមកកាន់អង្គប្រជុំប្រចាំខែលើកទី១០ ។

**កិច្ចការទី ៧៖**

សរសេរភាពរីកចម្រើនរបស់សិស្សក្នុងឆ្នាំសិក្សា ដើម្បីផ្ញើជូនមាតាបិតាសិស្ស ។

# កិច្ចការវាយតម្លៃទី 1
## សន្លឹកព័ត៌មានសិស្សសម្រាប់ការវាយតម្លៃកម្រងស្នាដៃសិស្ស

| សំណួរ | ព័ត៌មានលំអិតរបស់កុមារ |
|---|---|
| ***លក្ខណៈផ្ទាល់ខ្លួន***<br>១. នាមកុមារ<br>២. អាយុ<br>៣. ភេទ | <br>១.<br>២.<br>៣. |
| ***ប្រវត្តិនៃការអប់រំ***<br>៤. កម្រិតថ្នាក់ ក្នុងឆ្នាំសិក្សា (ឆ្នាំបច្ចុប្បន្ន)<br>៥. កម្រិតថ្នាក់ ក្នុងឆ្នាំសិក្សា (ឆ្នាំមុន)<br>៦. ឆ្នាំ ចាប់ផ្តើមថ្នាក់ទី១<br>៧. រៀនត្រួតថ្នាក់ ឬ បោះបង់ចោលការសិក្សា | <br>៤.<br>៥.<br>៦.<br>៧. គ្មាន  មាន |
| **វត្តមាន និងការចូលរួម**<br>៨.  អវត្តមានពីសាលារៀនឆ្នាំសិក្សា (ឆ្នាំបច្ចុប្បន្ន)<br>៩.  អវត្តមានពីសាលារៀនឆ្នាំសិក្សា (ឆ្នាំមុន)<br>១០.មូលហេតុនៃអវត្តមាន | <br>៨. មិនដែលសោះ  ម្តងម្កាល  ជារឿយៗ<br>៩. មិនដែលសោះ  ម្តងម្កាល  ជារឿយៗ<br>១០. ឈឺ ធ្វើការ ជួយមាតាបិតា  ផ្សេងៗ : ........................ |
| **ស្ថានភាពគ្រួសារ**<br>១១. មេគ្រួសារ (បុរស/ស្ត្រី)<br>១២. ចំនួនបងប្អូនបង្កើត<br>១៣. ចំនួនមនុស្សនៅក្នុងផ្ទះ<br>១៤.ប្រភេទផ្ទះ | <br>១១.<br>១២.<br>១៣.<br>១៤. ស្បូវ  ឈើ  ឥដ្ឋ ផ្សេងៗ : ................................... |
| **ស្ថានភាពសង្គម-សេដ្ឋកិច្ច**<br>១៥.ជាធម្មតាមានសៀវភៅ និងប៊ិក<br>១៦.មានសំលៀកបំពាក់រៀនត្រឹមត្រូវ<br>១៧.ជាធម្មតាពាក់ស្បែកជើង<br>១៨.ជិះកង់ទៅរៀន<br>១៩.ចំងាយសាលារៀន-ផ្ទះ | <br>១៥.  មាន    គ្មាន<br>១៦. មាន    គ្មាន<br>១៧. មាន    គ្មាន<br>១៨. មាន    គ្មាន<br>១៩. ជិត (តិចជាង១គ.ម) មធ្យម (១-៣គ.ម) ឆ្ងាយ (ឆ្ងាយជាង ៣គ.ម) |
| **សុខភាព**<br>២០.មានកំពស់ និងទំងន់មធ្យម<br>២១,ប្រុងស្មារតី និងមានថាមពលនៅក្នុងថ្នាក់<br>២២,ការមើលឃើញ និងស្តាប់ឮ មធ្យម | <br>២០.   កំពស់...          ទម្ងន់...<br>២១.   ទុយមុយ          ក្លាហាន<br>២២.   មាន    គ្មាន (បើមានគួរបញ្ជាក់ ).... |
| **សង្គម/ឥរិយាបថ អាកប្បកិរិយា**<br>២៣,មានមិត្តភ័ក្តិជាច្រើននៅសាលារៀន<br>២៤,មានភាពរីករាយនៅសាលារៀន | <br>២៣.   មាន   គ្មាន<br>២៤.   មាន   គ្មាន |

# កិច្ចការវាយតម្លៃទី 2 3 4 និង 5

## បញ្ជីផ្ទៀងផ្ទាត់សម្រាប់ប្រមូលកម្រងស្នាដៃសិស្ស

| ការប្រមូលលើកទី | ផ្នែក | គំរូបានប្រមូល | យោបល់ |
|---|---|---|---|
| ១ | សំណេរ | មាន គ្មាន | |
| (ជាកិច្ចការទី២ | នព្វន្ត | មាន គ្មាន | |
| សម្រាប់ការប្រជុំ ប្រចាំខែ លើកទី២) | គំនូរ | មាន គ្មាន | |
| ២ | សំណេរ | មាន គ្មាន | |
| (ជាកិច្ចការទី៣ | នព្វន្ត | មាន គ្មាន | |
| សម្រាប់ការប្រជុំ ប្រចាំខែ លើកទី៤) | គំនូរ | មាន គ្មាន | |
| ៣ | សំណេរ | មាន គ្មាន | |
| (ជាកិច្ចការទី៤ | នព្វន្ត | មាន គ្មាន | |
| សម្រាប់ការប្រជុំ ប្រចាំខែ លើកទី៧) | គំនូរ | មាន គ្មាន | |
| ៤ | សំណេរ | មាន គ្មាន | |
| (ជាកិច្ចការទី៥ | នព្វន្ត | មាន គ្មាន | |
| សម្រាប់ការប្រជុំ ប្រចាំខែ លើកទី៩) | គំនូរ | មាន គ្មាន | |

# កិច្ចការវាយតម្លៃទី 6

**សិក្សាករណីដំណើររឿងរបស់** ......................................

| សិក្សាករណីដំណើររឿងរបស់កុមារ | |
|---|---|
| **នាមកុមារ អាយុ ភេទ** | ចូរប្រើព័ត៌មាន ពីសន្លឹកព័ត៌មាន ( សំណួរ ១-៣) |
| **ប្រវត្តិនៃការអប់រំ** | ចូរប្រើព័ត៌មាន ពីសន្លឹកព័ត៌មាន ( សំណួរ ៤-១០) |
| **ស្ថានភាពគ្រួសារ** | ចូរប្រើព័ត៌មាន ពីសន្លឹកព័ត៌មាន ( សំណួរ ១១-១៩) |
| **កុមារនៅសាលារៀន** | ចូរប្រើព័ត៌មាន ពីសន្លឹកព័ត៌មាន ( សំណួរ ២០-២៤) |
| **ការរៀនសូត្ររបស់កុមារ** | **ភស្តុតាងនៃការវាយតម្លៃកម្រងស្នាដៃសិស្ស ( ផ្លូវការ)** |
| **សំណេរ**(រីកចម្រើន/មានបញ្ហា) | |
| **នព្វន្ត**(រីកចម្រើន/ មានបញ្ហា) | |
| **គំនូរ**(រីកចម្រើន/មានបញ្ហា) | |

# កិច្ចការវាយតម្លៃទី 6

## សិក្សាករណីចំណើរឿងកុមារ ( ត)

| ឥរិយាបថ | ភស្តុតាងពីការសង្កេតមិនផ្លូវការរបស់គ្រូ |
|---|---|
| **លទ្ធផលនៃការសិក្សា និងការចូលរួមគ្រប់មុខវិជ្ជា**<br>(ឧទាហរណ៍: រៀនពូកែគ្រប់មុខវិជ្ជា មុខវិជ្ជាខ្លះពូកែជាងមុខវិជ្ជាខ្លះទៀត) | |
| **បំណិនការងារក្រុម**<br>(ឧទាហរណ៍: ការងារជាក្រុម ជាមួយកុមារដទៃទៀត) | |
| **ការសំដែងអំពីខ្លួនឯង**<br>(ឧទាហរណ៍: អាចនិយាយអំពីគំនិត និងមតិរបស់ខ្លួន ស្នាដៃក្នុងការសរសេរ ការបង្ហាញបែបសិល្បៈ) | |
| **ការទទួលខុសត្រូវ**<br>(ឧទាហរណ៍: ជួយកិច្ចការក្នុងថ្នាក់ បោសសំអាត...) | |
| **ភាពជឿជាក់លើខ្លួនឯង/ភាពឯករាជ្យ**<br>(ឧទាហរណ៍: សួរសំណួរទៅកាន់គ្រូ អាចរៀនដោយខ្លួនឯងយ៉ាងសកម្មនៅក្នុងថ្នាក់) | |
| **យកចិត្តទុកដាក់ចំពោះអ្នកដទៃ**<br>(ឧទាហរណ៍: ជួយកុមារដទៃ ជួយកុមារតូចៗ) | |
| **យោបល់ទូទៅ**<br>(ឧទាហរណ៍: កម្រិតនៃការសិក្សាជាទូទៅ បំណិន ឬ សមត្ថភាព សមរម្យបានឡើងថ្នាក់ ភាពរីករាយនៅសាលា...) | |

## ៧.២ : លទ្ធផលនៃការវាយតម្លៃ

### ព័ត៌មានសម្រាប់គ្រូ

នៅដំណាច់ឆ្នាំសិក្សានីមួយៗ គ្រូធ្វើការវាយតម្លៃសិស្ស : តើពួកគេត្រូវឡើងថ្នាក់ ឬត្រូវរៀនត្រួតថ្នាក់ ? នេះជាការសម្រេចចិត្តយ៉ាងសំខាន់ ។ សិស្សដែលមានសមត្ថភាពគ្រប់គ្រាន់ត្រូវតែបានឡើងថ្នាក់ ពីព្រោះការរៀនត្រួតថ្នាក់ គឺជាមូលហេតុចំបងនៃការបោះបង់ការសិក្សា ។ ប្រសិនបើសិស្សពិតជាពុំយល់អំពីមេរៀនដែលខ្លួនបានរៀននៅក្នុងថ្នាក់បច្ចុប្បន្នទេ នោះពុំអាចឱ្យពួកគេឡើងថ្នាក់ទេ ពីព្រោះពួកគេមិនអាចយល់ និងមិនអាចធ្វើកិច្ចការលើការរៀនសូត្រទៅថ្នាក់ខ្ពស់បានឡើយ ។

គ្រូដែលអនុវត្តការវាយតម្លៃមិនផ្លូវការ និងវាយតម្លៃជាដំណាក់ៗក្នុងឆ្នាំសិក្សា បានដឹងយ៉ាងច្បាស់រួចទៅហើយអំពីស្នាដៃរបស់សិស្ស ។ គ្រូប្រហែលជាបានបង្រៀនបំប៉នសិស្សទាំងនេះរួចហើយដែរ ដើម្បីជួយពួកគេឱ្យអភិវឌ្ឍបំណិនរបស់ខ្លួន ។ គ្រូគួរតែដឹងអំពីលទ្ធផលរៀនសូត្ររបស់សិស្ស នៅពេលវាយតម្លៃដំណាច់ឆ្នាំសិក្សា ។ **គ្រូមិនគួរពឹងផ្អែកតែទៅលើលទ្ធផលតេសចុងឆ្នាំមួយមុខ ដើម្បីធ្វើការសម្រេចចិត្តអំពីការឡើងថ្នាក់ឡើយ** ព្រោះជួនកាលសិស្សពុំទទួលបានពិន្ទុល្អក្នុងការធ្វើតេស្ត ដោយសារពួកគេពុំស្រួលខ្លួនភ័យពេក ឬដោយការធ្វេសប្រហែសអ្វីមួយ ។

គ្រូដែលបានប្រមូលកិច្ចការសិស្សក្នុងឆ្នាំសិក្សា អាចជាភស្តុតាងជាក់ស្តែងខ្លះៗនៅចុងឆ្នាំសិក្សា សម្រាប់ជួយគាត់ធ្វើការសម្រេចចិត្ត ។ ហេតុនេះហើយបានជាកម្រងស្នាដៃសិស្សមានសារសំខាន់ ។ គ្រូដែលបានរក្សាទុកកម្រងស្នាដៃសិស្សចំនួន ៥ នាក់ជាគំរូកិច្ចការសិស្សធ្វើជាភស្តុតាងនៃស្នាដៃសិស្ស ។ ជួនកាលគំរូកិច្ចការសិស្ស អាចបញ្ជាក់អំពីស្នាដៃប្រសើរជាងពិន្ទុនៅក្នុងការធ្វើតេស្ត ។

### កិច្ចការគ្រូ

#### កិច្ចការវាយតម្លៃទី 7

គ្រូពិនិត្យឡើងវិញនូវគំរូកិច្ចការសិស្ស នៅក្នុងកម្រងស្នាដៃសិស្សទាំងប្រាំ ។ តើសិស្សមានភាពរីកចម្រើនជឿនលឿនអ្វីខ្លះនៅក្នុងឆ្នាំសិក្សានេះ ? សរសេរយោបល់ខ្លីមួយអំពីភាពជឿនលឿនរបស់សិស្សទាំងប្រាំនាក់ក្នុងឆ្នាំសិក្សា ដោយផ្អែកទៅលើភស្តុតាងនៃគំរូកិច្ចការ ។ សរសេរយោបល់អំពីសិស្សម្នាក់ៗ ទៅក្នុងកម្រងស្នាដៃសិស្សសមស្រប ។

នៅពេលគ្រូនិងសាលារៀនបានសម្រេចចិត្តអំពីការឱ្យឡើងថ្នាក់/រៀនត្រួតថ្នាក់ហើយ គ្រូអាចផ្តល់កម្រងស្នាដៃសិស្សទៅឱ្យមាតាបិតា/គ្រួសារសិស្សម្នាក់ៗ ។ គ្រូអាចនិយាយជាមួយមាតាបិតាសិស្សអំពីភាពរីកចម្រើនរបស់សិស្ស លើការរៀនសូត្រក្នុងឆ្នាំសិក្សា នៅពេលផ្តល់កម្រងស្នាដៃសិស្សទៅគាត់ ។

## កិច្ចការវាយតម្លៃទី៧ : ភាពរីកចម្រើនរបស់សិស្សក្នុងឆ្នាំសិក្សា

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

✂..........................................................................................................................................................

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

✂..........................................................................................................................................................

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

## កិច្ចការ : ភាពរីកចម្រើនរបស់សិស្សក្នុងឆ្នាំសិក្សា (ត)

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

✂.......................................................................................................................................................

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

✂.......................................................................................................................................................

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

## កិច្ចការ : ភាពរីកចម្រើនរបស់សិស្សក្នុងឆ្នាំសិក្សា (ត)

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

✂.........................................................................................................................................................

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

✂.........................................................................................................................................................

| ឈ្មោះ | ភេទ : |
|---|---|
| ភាពរីកចម្រើនក្នុងមុខវិជ្ជាភាសាខ្មែរ | |
| ភាពរីកចម្រើនក្នុងមុខវិជ្ជាគណិតវិទ្យា | |
| ភាពរីកចម្រើនទូទៅ | |

## ៨.ប្រធានបទទី៨ : ការឆ្លុះបញ្ចាំងគ្រូ ( ស្វ័យវាយតម្លៃ)

### ព័ត៌មានសម្រាប់គ្រូ

ការឆ្លុះបញ្ចាំង គឺជាការអនុវត្តជាក់ស្តែងមួយ ដែលគ្រូល្អៗភាគច្រើនធ្វើវាជាទម្លាប់ ។ វាមានន័យថាពួកគេពិចារណាជាទៀងទាត់អំពីភាពរីកចម្រើនជឿនលឿនរបស់សិស្សនៅក្នុងថ្នាក់គាត់ ក្នុងនាមជាអ្នកបង្រៀន ។ ជានិច្ចកាលគ្រូត្រូវសួរសំណួរដល់ខ្លួនឯងថា :

-តើសិស្សគ្រប់គ្នារៀនបានពូកែឬទេ ?

-តើអ្វីដែលសិស្សជួបការលំបាក ? តើអ្វីដែលជាមូលហេតុនៃការលំបាករបស់ពួកគេ ?

-តើសិស្សគ្រប់គ្នានៅក្នុងថ្នាក់ចាប់អារម្មណ៍នឹងមេរៀននេះឬទេ ?

-តើសិស្សទាំងអស់មករៀនទៀងទាត់មានភាពរីករាយនឹងអ្វីដែលពួកគេរៀនឬទេ ?

ជាធម្មតាមានកុមារខ្លះដែលត្រូវការយកចិត្តទុកដាក់បន្ថែម ។ ការឆ្លុះបញ្ចាំងគ្រូ គឺជាការវាយតម្លៃដោយខ្លួនឯង ។ គោលបំណងសំខាន់នៃការឆ្លុះបញ្ចាំងគ្រូ គឺគិតអំពីសំណួរនៅក្នុងប្រអប់ខាងក្រោមនេះ

| |
|---|
| *តើខ្ញុំអាចផ្លាស់ប្តូរ ទម្លាប់បង្រៀនរបស់ខ្ញុំដោយវិធីណាដើម្បីកែលំអការរៀនសូត្ររបស់កុមារនៅក្នុងថ្នាក់របស់ខ្ញុំ?* |

ការឆ្លុះបញ្ចាំងគ្រូ គឺការផ្លាស់ប្តូរទម្លាប់របស់គ្រូខ្លួនឯងផ្ទាល់ ដើម្បីទទួលបាន លទ្ធផលល្អ ។

ពេលគ្រូសម្រេចនូវអ្វីដែលពួកគាត់នឹងធ្វើខុសពីមុន បន្ទាប់មកគាត់ត្រូវបង្កើតផែនការអនុវត្ត ។ គ្រូគួរតែធ្វើកិច្ចតែងការរៀបចំសកម្មភាពរៀនជាក្រុមតូចៗ យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ។ រៀបចំសកម្មភាពរៀនសូត្រនៅខាងក្រៅបន្ទប់រៀនយ៉ាងហោចណាស់ម្តង ឬ ពីរដងក្នុងមួយសប្តាហ៍ និងប្រមូលដាក់តាំងគំនូររបស់សិស្ស ។ នៅពេលគ្រូសាកល្បងគំនិតថ្មីៗ គាត់គួរតែឆ្លុះបញ្ចាំងម្តងទៀត : តើវាដំណើរការឬទេ? តើកុមារចូលចិត្តវាទេ? តើវាបានជួយកុមារឱ្យអភិវឌ្ឍការយល់ដឹងនិងបំណិនថ្មីឬទេ? ប្រសិនបើសិស្សទទួលអត្ថប្រយោជន៍ពីគំនិតថ្មីនេះ នោះគ្រូគួរតែអនុវត្តទម្លាប់បង្រៀនពីគំនិតថ្មីនោះ ។ ជួនកាលនៅពេលសាកល្បងគំនិតថ្មីៗ គាត់នឹងអាចគិតពិចារណាអំពីគំនិតថ្មីដទៃទៀត ។ រួចសាកល្បងវាតាមវិធីដូចគ្នា ។ ដូច្នេះគ្រូបានចាប់ផ្តើមកែប្រែ និងកែលំអទម្លាប់ចាស់ ។ ជំហានសម្រាប់អនុវត្ត :

- ឆ្លុះបញ្ចាំងលើបញ្ហាដែលកុមារមាននៅក្នុងថ្នាក់
- ពិចារណាអំពីវិធីផ្លាស់ប្តូរទម្លាប់បង្រៀនដែលនឹងជួយដោះស្រាយបញ្ហាទាំងនេះ
- ធ្វើផែនការប្រើវិធីថ្មីៗ
- អនុវត្តនៅក្នុងការបង្រៀន
- ពិចារណាអំពីថាតើវាទទួលបានជោគជ័យ ឬ មិនបានជោគជ័យ ។

ជួនកាលដំណើរការនេះហៅថា " វដ្តឆ្លុះបញ្ចាំងការបង្រៀន " ដូចដ្យាក្រាមខាងក្រោម :




ជួនកាល គេក៏គូរវាជារាងគូចខ្យងដែរ ដើម្បីបង្ហាញថាដំណើរការពុំមែនមានត្រឹមតែមួយវដ្តឡើយ...។ វាអាចជាដំណើរការបន្តគ្នាដែលអាចក្លាយទៅជាផ្នែកមួយនៃទម្លាប់បង្រៀន ។

## កិច្ចការគ្រូ

### កិច្ចការឆ្លុះបញ្ចាំងទី 1

រៀងរាល់ខែ ថ្ងៃមុនអង្គប្រជុំថ្ងៃព្រហស្បតិ៍ គ្រូគួរតែរកពេលដើម្បីឆ្លុះបញ្ចាំងពីបទពិសោធរបស់ខ្លួននៅក្នុងបន្ទប់រៀនកាលពីខែមុន ។ ពួកគាត់គួរតែកត់ត្រាការអនុវត្តថ្មីៗល្អជាងគេបី ដែលគាត់បានធ្វើ និងបន្ទាប់មកបញ្ហាធំជាងគេបី ដែលពួកគាត់ជួបប្រទះនៅក្នុងខែ ។ គ្រូគួរតែចែករំលែកបទពិសោធ និងគំនិតពួកគាត់នៅពេលប្រជុំប្រចាំខែ។

### កិច្ចការឆ្លុះបញ្ចាំងទី 2

នៅក្នុងការប្រជុំប្រចាំខែចុងក្រោយ គ្រូពិនិត្យមើលការកត់ត្រារបស់ខ្លួន និងសម្រេចចិត្តអំពីអ្វីដែលជាបញ្ហាប្រឈមធំៗ ជាងគេបីរបស់គាត់ និងការកែប្រែល្អជាងគេបីដែលគាត់បានធ្វើនៅក្នុងការអនុវត្តរបស់គាត់ក្នុងឆ្នាំសិក្សា ។ អ្នកសម្របសម្រួលនឹងជួយគ្រូក្នុងការសរុបព័ត៌មានទាំងអស់ ដើម្បីបង្កើតជាបញ្ជីសង្ខេបនូវបទពិសោធទាំងឡាយរបស់គាត់នៅជិតដំណាច់ឆ្នាំសិក្សា ។

# កិច្ចការឆ្លុះបញ្ចាំងគ្រូ ១ និង ២

| ខែ | គំនិតថ្មីល្អជាងគេ៣ដែលខ្ញុំបានធ្វើ | បញ្ហា៣ដែលខ្ញុំបានជួបប្រទះ |
|---|---|---|
| តុលា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| វិច្ឆិកា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| ធ្នូ | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| មករា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| កុម្ភៈ | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| មីនា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |

| | | |
|---|---|---|
| មេសា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| ឧសភា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| មិថុនា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| កក្កដា | ១.<br>២.<br>៣. | ១.<br>២.<br>៣. |
| **ឆ្នាំសិក្សា** | **ការផ្លាស់ប្តូរធំជាងគេ៣ដែលខ្ញុំបានធ្វើ** | **បញ្ហាធំជាងគេ៣ដែលខ្ញុំបានជួបប្រទះ** |
| **២០០...-<br>២០០...** | ១.<br>២.<br>៣. | ១.<br>២.<br>៣. |

# អំណះអំណាងរបស់គ្រូ

ការងារមាននៅក្នុង**សៀវភៅកំណត់ត្រាគ្រូ**នេះ គឺជាកម្មសិទ្ធិផ្ទាល់ខ្លួនខ្ញុំ ។ វាត្រូវបានផ្អែកទៅលើការសង្កេតក្នុងបន្ទប់រៀន កិច្ចតែងការបង្រៀន បទពិសោធបង្រៀន និងការវាយតម្លៃការបង្រៀន ដែលខ្ញុំ បានធ្វើក្នុងឆ្នាំសិក្សាន្លងមក ។

ខ្ញុំសូមប្រគល់ជូន**សៀវភៅកំណត់ត្រាគ្រូ**នេះដោយស្ម័គ្រចិត្តទៅឱ្យអ្នកគ្រប់គ្រងធ្វើការពិនិត្យ ។ ខ្ញុំយល់ថាសៀវភៅនេះនឹងមិនត្រូវបានគេធ្វើការកែតម្រូវអ្វីឡើយ ។ គោលបំណងនៃការពិនិត្យ គឺដើម្បីមើលថាតើខ្ញុំបានបំពេញគ្រប់កិច្ចការទាំងអស់ឬទេ ។ អ្នកគ្រប់គ្រងខ្ញុំនឹងប្រគល់សៀវភៅកំណត់ត្រាគ្រូនេះ ត្រឡប់មកឱ្យខ្ញុំវិញបន្ទាប់ពីបានពិនិត្យរួច ខ្ញុំនឹងរក្សាវាសម្រាប់ជាឯកសារនៃការងារអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្ញុំក្នុងឆ្នាំសិក្សានេះ ។

ហត្ថលេខា : ______________________ គ្រូ ______________ ថ្ងៃប្រគល់ជូន

______________ ថ្ងៃប្រគល់ត្រឡប់មកវិញ

# អំណះអំណាងរបស់អ្នកគ្រប់គ្រង

**សៀវភៅកំណត់ត្រាគ្រូ**នេះ ត្រូវបានប្រគល់ជូនដោយស្ម័គ្រចិត្ត ។ ខ្ញុំបានអានវា និងបានរកឃើញថា :

រាល់កិច្ចការទាំងអស់ត្រូវបានបំពេញចប់សព្វគ្រប់ ☐

រាល់កិច្ចការទាំងអស់ពុំទាន់បានបំពេញចប់សព្វគ្រប់នៅឡើយទេ ☐

**សៀវភៅកំណត់ត្រាគ្រូ**ត្រូវបានប្រគល់ត្រឡប់ទៅគ្រូវិញ ។ ☐

ហត្ថលេខា : ________________________ អ្នកគ្រប់គ្រង

មុខតំណែង: ________________________ __________ ថ្ងៃខែឆ្នាំប្រគល់ត្រឡប់

# ឧបសម្ព័ន្ធ

# កម្មវិធីបំប៉នឯកសារប្រសិទ្ធភាពនៃការបង្រៀន និង រៀន ក្នុងឆ្នាំសិក្សា

| ខែ | កញ្ញា ៩ | តុលា ១០ | វិច្ឆិកា ១១ | ធ្នូ ១២ | មករា ១ | កុម្ភៈ ២ | មីនា ៣ | មេសា ៤ | ឧសភា ៥ | មិថុនា ៦ | កក្កដា ៧ | សីហា ៨ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ការបំប៉ន ជាប់ៗគ្នា** | ៦ ថ្ងៃ បំប៉នគ្រូឧទ្ទេស និង ៦ ថ្ងៃ បំប៉នគ្រូបង្រៀន | | | | | | | សិក្ខាសាលា វាយតម្លៃ ១ថ្ងៃសម្រាប់ គ្រូ | | | សិក្ខាសាលា វាយតម្លៃ ១ថ្ងៃសម្រាប់ គ្រូ | |
| **ប្រជុំប្រចាំខែ** | | ប្រជុំ១ ១ថ្ងៃ | ប្រជុំ២ ១ថ្ងៃ | ប្រជុំ៣ ១ថ្ងៃ | ប្រជុំ៤ ១ថ្ងៃ | ប្រជុំ៥ ១ថ្ងៃ | ប្រជុំ៦ ១ថ្ងៃ | ប្រជុំ៧ ១ថ្ងៃ | ប្រជុំ៨ ១ថ្ងៃ | ប្រជុំ៩ ១ថ្ងៃ | ប្រជុំ១០ ១ថ្ងៃ | |
| **អនុវត្តក្នុងថ្នាក់រៀន** | | ការអនុវត្តក្នុងថ្នាក់រៀន ពេញមួយឆ្នាំសិក្សា ទាក់ទងនឹងការសង្កេត និងកិច្ចការសរសេរងាយៗ រៀងរាល់អង្គប្រជុំប្រចាំខែដែលត្រូវពិនិត្យឡើងវិញនៅពេលប្រជុំខែបន្ទាប់ ។ គ្រូជួបគ្នាក្រៅផ្លូវការចន្លោះការប្រជុំប្រចាំខែ សម្រាប់ជាផ្នែកនៃបណ្តាញសាលារៀន ដែលពួកគាត់បង្កើតដោយខ្លួនឯង ទៅតាមស្ថានភាពមូលដ្ឋានរបស់គាត់ ។ | | | | | | | | | | |

ការបំប៉នជាប់ៗគ្នា : ៦ថ្ងៃ + ១ថ្ងៃ + ១ថ្ងៃ (* វាយតម្លៃ/ធ្វើផែនការ " ឆ្លុះបញ្ចាំងការងារកន្លងមក និងធ្វើផែនការបន្ត ")

ការប្រជុំប្រចាំខែ : ១០ថ្ងៃ (ទាក់ទងនឹងការពិនិត្យកិច្ចការឡើងវិញ ខ្លឹមសារថ្មី សកម្មភាព និងការរៀបចំកិច្ចការ)

ការអនុវត្តក្នុងបន្ទប់រៀន : សាកល្បងគំនិតថ្មីៗ ធ្វើកិច្ចការងាយៗ ការសន្ទនាជាមួយគ្រូគ្នាឯង ... ។

# បញ្ជីកិច្ចការតាមប្រធានបទត្រូវធ្វើប្រចាំឆ្នាំ

| ល.រ | ប្រធានបទ | កិច្ចការ | ចំណងជើង | ពេលកំណត់ | បានពិភាក្សា | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ការគ្រប់គ្រងបន្ទប់រៀន | ១ | ប្លង់បន្ទប់រៀន ១ | ដើមខែតុលា | ប្រជុំខែតុលា | |
| | | ២ | ប្លង់បន្ទប់រៀន ២ និងការប្រែប្រួល | ដើមខែមីនា | ប្រជុំខែមីនា | |
| | | ៣ | ប្លង់បន្ទប់រៀន ៣ និងការប្រែប្រួល | ដើមខែមិថុនា | ប្រជុំខែមិថុនា | |
| ២ | សំណួរពិចារណាហ្មត់ចត់ | ១ | ការពិចារណាហ្មត់ចត់ ១ | ដើមខែមករា | ប្រជុំខែមករា | |
| | | ២ | ការពិចារណាហ្មត់ចត់ ២ | ដើមខែកុម្ភៈ | ប្រជុំខែកុម្ភៈ | |
| ៣ | ល្បែងសិក្សា | ១ | ល្បែងសិក្សា ១ គណិតវិទ្យា | ដើមខែវិច្ឆិកា | ប្រជុំខែវិច្ឆិកា | |
| | | ២ | ល្បែងសិក្សា ២ ភាសា | ដើមខែធ្នូ | ប្រជុំខែធ្នូ | |
| | | ៣ | ល្បែងសិក្សា ៣ សិក្សាសង្គម | ដើមខែកុម្ភៈ | ប្រជុំខែកុម្ភៈ | |
| | | ៤ | ល្បែងសិក្សា ៤ វិទ្យាសាស្ត្រអនុវត្ត | ដើមខែមេសា | ប្រជុំខែមេសា | |
| ៤ | ការវាយតម្លៃ | ១ | ជ្រើសរើសសិស្សដើម្បីរៀបចំកម្រងស្នាដៃ | ដើមខែតុលា | ប្រជុំខែតុលា | |
| | | ២ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែវិច្ឆិកា | ប្រជុំខែវិច្ឆិកា | |
| | | ៣ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែកុម្ភៈ | ប្រជុំខែកុម្ភៈ | |
| | | ៤ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែមេសា | ប្រជុំខែមេសា | |
| | | ៥ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែមិថុនា | ប្រជុំខែមិថុនា | |
| | | ៦ | -សិក្សាករណីដំណើររឿងសិស្ស-ប្រជុំ<br>-សិក្សាករណីដំណើររឿងសិស្ស-ពង្រាង | សិក្ខាសាលា១ថ្ងៃ ខែមេសា | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |
| | | ៧ | ពិនិត្យឡើងវិញនូវកម្រងស្នាដៃសិស្ស | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |
| ៥ | ការប្រើធនធានសំបូរបែបក្នុងថ្នាក់រៀន | ១ | ប្រើផ្ទាំងរូបភាព | ដើមខែវិច្ឆិកា | ប្រជុំខែវិច្ឆិកា | |
| | | ២ | ប្រើផែនទី | ដើមខែមករា | ប្រជុំខែមករា | |
| ៦ | អំណាន | ១ | អំណាន ១ | ដើមខែធ្នូ | ប្រជុំខែធ្នូ | |
| | | ២ | អំណាន ២ | ដើមខែមករា | ប្រជុំខែមករា | |
| ៧ | សំណេរ | ១ | សំណេរ ១ ពង្រាង និងប្រជុំ | ដើមខែមីនា | ប្រជុំខែមីនា | |
| | | ២ | សំណេរ ២ អត្ថបទចរចា | ដើមខែមេសា | ប្រជុំខែមេសា | |
| ៨ | ការឆ្លុះបញ្ចាំង គ្រូ | ១ | ការឆ្លុះបញ្ចាំងគ្រូប្រចាំឆ្នាំ | សិក្ខាសាលា១ថ្ងៃ | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |
| | | ២ | ឆ្លុះបញ្ចាំងការងារកន្លងមក និងធ្វើផែនការបន្ត | សិក្ខាសាលា១ថ្ងៃ | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |

**កំណត់សំគាល់** : ក្នុងកូឡោនផ្សេងៗ គ្រូត្រូវគូសជាសញ្ញា ✓ នូវកិច្ចការដែលបានធ្វើហើយ ។

# សន្ទានុក្រមនៃពាក្យគន្លឹះប្រើនៅក្នុងឯកសារ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន

| ពាក្យ | សេចក្តីពន្យល់ |
|---|---|
| **ការរៀនផ្អែកលើសកម្មភាព** | នៅពេលកុមារត្រូវបញ្ចប់កិច្ចការមួយ និងបង្កើតលទ្ធផល ដើម្បីបង្ហាញពីការរៀនសូត្រ ( ការស្តាប់គ្រូ និងការចម្លងពីក្តារខៀន ពុំមែនជាការផ្អែកលើសកម្មភាពឡើយ) |
| **ការវាយតម្លៃ (Assessment)** | ការវិនិច្ឆ័យអំពីការរីកចម្រើនជឿនលឿន ឬ ស្នាដៃរបស់កុមារដោយផ្អែកលើភស្តុតាង ។ |
| **ការរៀនតាមវិធីសិស្សមជ្ឈមណ្ឌល** | វិធីបង្រៀន និងរៀនដែលសង្កត់ទៅលើការចូលរួមរបស់កុមារ ជាពិសេសចំណាប់អារម្មណ៍ ការចង់ឃើញចង់ដឹង គំនិត និងមតិរបស់ពួកគេ ។ |
| **ការប្រជុំ** | ដំណើរការដែលអ្នកសរសេរចែករំលែកសំណេរព្រាងមួយជាមួយអ្នកអានដែលផ្តល់យោបល់កែលំអអំពីគុណភាពរបស់អត្ថបទ ។ |
| **របៀបអានអក្សរ** | ច្បាប់មូលដ្ឋានដែលគេត្រូវដឹង ដើម្បីអាចអានបាន ( ឧទាហរណ៍ៈ អត្ថបទខ្មែរត្រូវអានពីលើចុះ ក្រោម ពីឆ្វេងទៅស្តាំ ពីខាងមុខសៀវភៅទៅខាងក្រោយ សៀវភៅ) ។ |
| **សំណួរពិចារណាហ្មត់ចត់** | សំណួរដែលតម្រូវឱ្យកុមារគិតពិចារណាអំពីព័ត៌មាន ឬគំនិតមួយ ឬច្រើន និងជាលទ្ធផល **បង្កើតបានជាព័ត៌មាន ឬ គំនិតថ្មីមួយ** ។ |
| **សេចក្តីព្រាង** | អត្ថបទ ឬ សំណេរដែលអ្នកសរសេរព្យាយាមកែលំអវា ។ |
| **ការធ្វើឱ្យសំបូរបែប/ការពង្រីកបន្ថែម** | សកម្មភាពរៀនសូត្រអពីប្រធានបទជាក់លាក់មួយសម្រាប់សិស្សដោយពង្រីកបន្ថែមអ្វី ដែលពួកគេបានរៀនរួចហើយ ។ |
| **ការវាយតម្លៃ (Evaluation)** | ការវាយតម្លៃចុងក្រោយអំពីលទ្ធផល ឬ ស្នាដៃរបស់សិស្ស ឬក្រុមសិស្ស ឬកម្មវិធីរៀនសូត្រមួយ ។ |
| **សេចក្តីព្រាងចុងក្រោយ** | អត្ថបទដែលអ្នកសរសេរជឿថាបានបញ្ចប់ ប៉ុន្តែគាត់នៅតែស្វែងរកដំបូន្មាន ។ |
| **ការវាយតម្លៃផ្លូវការ** | ការវាយតម្លៃដែលរៀបចំដោយប្រុងប្រយ័ត្នជាមុន ហើយដែលលទ្ធផលរបស់វា ត្រូវបានចងក្រងជាឯកសារ និងប្រើជារឿយៗក្នុងគោលបំណងជាផ្លូវការ ឬជាសាធារណៈ ។ |
| **ការវាយតម្លៃតាមដំណាក់ៗ** | ការវាយតម្លៃដែលធ្វើឡើងនៅក្នុងវគ្គសិក្សាដើម្បីកំណត់ពីភាពជឿនលឿនរបស់សិស្ស ដោយប្រៀបធៀបជាមួយគោលបំណង និង វត្ថុបំណងនៃការរៀនសូត្រ ឬជាមួយ សិស្សដទៃទៀតនៅក្នុងថ្នាក់ ។ |
| **ការរៀនដោយខ្លួនឯង** | ការរៀនម្នាក់ឯង ឬជួនកាលរៀនជាក្រុមកុមារដោយពុំមានវត្តមានគ្រូ ។ |

| | |
|---|---|
| **ការវាយតម្លៃក្រៅផ្លូវការ** | ការវាយតម្លៃក្នុងខណៈដែលមានសកម្មភាពជាប្រចាំដោយផ្អែកលើការសង្កេតអំពី ទង្វើក្នុងសកម្មភាពរៀនសូត្រ និងអត្តចរិតទូទៅ ។ |
| **សំណួរចងចាំ** | សំណួរដែលតម្រូវ ឱ្យកុមារចងចាំអ្វីមួយដែលពួកគេបានទទួល បទពិសោធ ឬ បានរៀនពីមុនមក និង និយាយអំពីវា ។ |
| **ការរៀនជាមួយគ្នាឯង (ជាក្រុម)** | ការរៀនដែលធ្វើឡើងរវាងកុមារ/មនុស្សធំដែលមានបទពិសោធន៍ និងឋានៈស្មើគ្នា ឬប្រហែលគ្នា ។ |
| **អត្ថបទចរចា** | ដំណើរការធ្វើការសម្រេចចិត្តអំពីអ្វីដែលត្រូវសរសេរបន្ទាប់ពីពិភាក្សា រវាងគ្រូ-សិស្ស ឬ នៅក្នុងក្រុមសិស្ស (ជារឿយៗប្រើសម្រាប់ជួយសិស្សដែលពុំទាន់ចាប់ផ្តើមសរសេរនៅឡើយ ដើម្បីឱ្យចូលរួមក្នុងដំណើរការសរសេរ) ។ |
| **សំណួរ (ការសួរសំណួរ)** | សូមមើលសំណួរចងចាំ យល់ដឹង និងពិចារណាហ្មត់ចត់ ។ |
| **ការឆ្លុះបញ្ចាំង** | សូមមើលការឆ្លុះបញ្ចាំងគ្រូខាងក្រោម ។ |
| **ការពង្រឹងបន្ថែម** | សកម្មភាពបន្ថែមផ្តល់ដល់សិស្ស ដើម្បីឱ្យពួកគេអាចអនុវត្តអ្វីមួយ ដែលបានរៀនរួចហើយ ។ |
| **ផលសម្រេចនៃការរៀនសូត្ររបស់សិស្ស** | ចំណេះដឹង និងបំណិន ដែលសិស្សអាចបកស្រាយនៅដំណាច់វគ្គសិក្សាបាន ។ |
| **កម្រងស្នាដៃសិស្ស** | បណ្តុំការងារដែលសិស្សធ្វើក្នុងរយៈពេលមួយ ។ ជារឿយៗប្រើដើម្បីជួយធ្វើការវាយតម្លៃការរៀនសូត្រ និងធ្វើជាគំរូការងារសិស្សដែលអាចផ្ញើឱ្យគ្រួសារពួកគេបាន ។ |
| **ការវាយតម្លៃសរុប** | ការវាយតម្លៃធ្វើនៅដំណាច់វគ្គសិក្សាដើម្បីកំណត់កម្រិតស្នាដៃរបស់សិស្ស ដោយធៀបទៅនឹងគោលបំណង និងវត្ថុបំណងរៀនសូត្រ ឬធៀបទៅនឹងសិស្សដទៃទៀតក្នុងថ្នាក់ ។ |
| **ការឆ្លុះបញ្ចាំងគ្រូ** | ដំណើរការនៃការវាយតម្លៃខ្លួនឯង ដោយគ្រូពិចារណាអំពីវិធី ដែលគាត់អាចកែប្រែទម្លាប់បង្រៀនរបស់គាត់ ដើម្បីកែលំអផលសម្រេច នៃការរៀនសូត្ររបស់សិស្ស។ |
| **សំណួរយល់ដឹង** | សំណួរដែលតម្រូវឱ្យសិស្សពិចារណាអំពីអត្ថន័យរបស់ព័ត៌មាន ឬ គំនិត មួយ និងពន្យល់វា ។ |
| **លំនាំសំណេរ** | អ្វីដែលអ្នកសរសេរធ្វើ ដើម្បីផលិតនូវសំណេរមានគុណភាពល្អ។ លំនាំនេះជាធម្មតាចាប់ផ្តើមពី ការកត់ត្រា បន្ទាប់មកប្លង់គ្រោង បន្ទាប់មកទៀត សេចក្តីព្រាងមួយចំនួន រហូតដល់បញ្ចប់សេចក្តីព្រាងចុងក្រោយ។ អ្នកសរសេរជាធម្មតាចែករំលែកសំណេរព្រាង ជាមួយអ្នកដទៃទៀត ដើម្បីធានាថាវាមានអត្ថន័យច្បាស់លាស់ និងធ្វើការកែតម្រូវមុននឹងផលិតនូវសេចក្តីព្រាងចុងក្រោយ។ |

# ការប្រជុំប្រចាំខែ

**សម្ភារ** ៖ សៀវភៅកំណត់ត្រាគ្រូ តារាងទី១: របៀបវារៈគំរូ សម្រាប់ការប្រជុំប្រចាំខែ

អ្នកសម្របសម្រួលនិយាយថា ៖ ការប្រជុំប្រចាំខែមានសារសំខាន់ពីព្រោះវាជាឱកាស

- នៅពេលគ្រូមកពីសាលារៀនផ្សេងៗគ្នា អាចផ្លាស់ប្តូរបទពិសោធន៍គ្នា
- សម្រាប់គ្រូរៀនពីគ្នាទៅវិញទៅមក (ខ្សែបណ្តាញគ្រូគ្នាឯង)
- សម្រាប់គ្រូមានបទពិសោធន៍ជួយគ្រូថ្មីៗ
- សម្រាប់ពង្រីកគំនិតល្អៗពីសាលារៀនមួយទៅសាលារៀនមួយទៀតអំពីការបង្រៀន និងការរៀន

គោលបំណងសំខាន់នៃការប្រជុំប្រចាំខែគឺផ្តល់ជាវេទិកា ។ អ្នកសម្របសម្រួលមូលដ្ឋាន ( នាយក និងនាយករងកម្រង នាយក នាយករងសាលា និងប្រធានក្រុមបច្ចេកទេស ) មានតួនាទីសំខាន់នៅក្នុងការលើក ទឹកចិត្តគ្រូឱ្យនិយាយអំពីការអនុវត្ត របស់ពួកគាត់ និងបញ្ហាដែលពួកគាត់កំពុងតែជួបប្រទះ ។

អ្នកសម្របសម្រួលនិយាយថា៖ កិច្ចការគ្រូនឹងជួយផ្តល់រចនាសម្ព័ន្ធមួយ សម្រាប់ការប្រជុំប្រចាំខែ ។ គ្រូអាចចាប់ផ្តើម ការប្រជុំប្រចាំខែពួកគាត់ទាំងអស់គ្នា ប៉ុន្តែបន្ទាប់មកត្រូវបែងចែកតាមក្រុមកម្រិតថ្នាក់សម្រាប់ធ្វើសកម្មភាពឱ្យកាន់តែពិស្តារ ។ សកម្មភាពសំខាន់ពីរនៅតាមក្រុមកម្រិតថ្នាក់ គឺ ៖

១. និយាយអំពីកិច្ចការដែលគ្រូបានបំពេញនៅក្នុងខែមុន និងអំពីបទពិសោធន៍ពួកគាត់ទាំងល្អ និងទាំងមិនល្អ ។ គ្រូខ្លះ ដែលទទួលបានលទ្ធផលល្អ អាចប្រើសៀវភៅកំណត់ត្រារបស់គាត់ ប្រាប់គ្រូដទៃទៀតនូវអ្វីដែលគាត់បានធ្វើ ។ គ្រូផ្សេងទៀតអាចសួរគាត់ឱ្យធ្វើបង្ហាញសកម្មភាពសិក្សាខ្លះៗ ។ អ្នកសម្របសម្រួលមូលដ្ឋានអាចជួយដោយ ធ្វើការសង្ខេបគំនិតល្អៗផ្សេងៗគ្នា ដែលគ្រូបាន និងកំពុងតែប្រើ ។

២. និយាយអំពីកិច្ចការដែលគ្រូនឹងធ្វើនៅចន្លោះការប្រជុំប្រចាំខែនេះ និងខែបន្ទាប់ ។ នេះមានន័យថា អានការណែនាំទាំងអស់គ្នាមួយចប់ ពិភាក្សាវា និងព្រមព្រៀងលើអ្វីដែលគួរធ្វើ ។

អ្នកសម្របសម្រួលចែកគំរូរបៀបវារៈ នឹងនិយាយថា របៀបវារៈសម្រាប់ការប្រជុំប្រចាំខែអាចមានរាងដូចនេះ ៖

## គំរូរបៀបវារៈ    សម្រាប់ការប្រជុំប្រចាំខែ

| | ចំណាងជើងសកម្មភាព | ខ្លឹមសារសំខាន់ៗ | អ្នកសម្របសម្រួល/ប្រធាន | ពេល |
|---|---|---|---|---|
| ១ | ប្រជុំគ្រូ<br>(ថ្នាក់ទី១-៦ ទាំងអស់) | ព័ត៌មានពីក្រសួងអយក<br>ការណែនាំថ្នាក់ជាតិ<br>ការណែនាំថ្នាក់ខេត្ត<br>ការណែនាំថ្នាក់ស្រុក/កម្រង<br>ព័ត៌មានមូលដ្ឋានដទៃទៀត | នាយកកម្រង | ៦០ នាទី |
| | | **កម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀន**<br>ការពិភាក្សាទូទៅ ព័ត៌មានទូទៅ<br>ការរីកចម្រើន យោបល់កែលំអ | នាយកកម្រង និង<br>អ្នកសម្របសម្រួលមូលដ្ឋាន | |
| ២ | ក្រុមកម្រិតថ្នាក់ | ចែករំលែកលទ្ធផលកិច្ចការ<br>ការពិភាក្សាតាមក្រុមតូចៗ<br>ការជ្រើសរើសគំនិតល្អៗ | នាយករង/ប្រធានក្រុម<br>បច្ចេកទេស | ៦០ នាទី |
| ៤ | ក្រុមកម្រិតថ្នាក់ | **បទបង្ហាញ**<br>ការពន្យល់/ការធ្វើបង្ហាញអំពី<br>គំនិតបង្រៀនល្អៗ | គ្រូ | ៤៥ នាទី |
| ៥ | ក្រុមកម្រិតថ្នាក់ | **ការរៀបចំ** សម្រាប់ **កិច្ចការទៅអនាគត :**<br>-ការអានកិច្ចការ<br>-ការពិភាក្សាកិច្ចការ<br>-សំណួរ និងចម្លើយ | នាយករង/ប្រធានក្រុម<br>បច្ចេកទេស | ៤៥ នាទី |
| ៦ | ប្រជុំក្រុមទាំងមូល | **សកម្មភាពពិនិត្យឡើងវិញនៅអង្គប្រជុំ**<br>បញ្ហាដែលលេចឡើង<br>បញ្ហាសម្ភារ/ការផ្គត់ផ្គង់<br>បញ្ហាធ្វើផែនការ | នាយកកម្រង និង<br>អ្នកសម្របសម្រួលមូលដ្ឋាន | ៣០ នាទី |
| | | | | **៤ ម៉ោង** |

របៀបវារៈនេះគ្រាន់តែជាគំរូប៉ុណ្ណោះអាចធ្វើការផ្លាស់ប្តូរទៅតាមការជាក់ស្តែង ។ សកម្មភាពដែលបានដាក់ពណ៌ បញ្ជាក់ទាំងពីរជាសកម្មភាពដែលមានសារសំខាន់ជាងគេបំផុត សម្រាប់រក្សានូវកម្មវិធីប្រសិទ្ធភាពនៃ ការបង្រៀន និង រៀន និងមិនគួរជំនួសបានឡើយ ។